## ADB DISCLAIMER FOR TRANSLATED DOCUMENTS

This document has been translated from English in order to reach a wider audience. However, English is the official language of the Asian Development Bank and the English original of this document is the only authentic (that is, official and authoritative) text. Any citations must refer to the English original of this document.

## សេចក្តីអះអាងរបស់ ADB ចំពោះឯកសារបកប្រែនេះ

ឯកសារនេះត្រូវបានបកប្រែចេញពីភាសាអង់គ្លេស ដើម្បីផ្សព្វផ្សាយដល់សវនកៈឱ្យកាន់តែទូលំទូលាយ ។ ប៉ុន្តែ ភាសាអង់គ្លេសគឺជាភាសាផ្លូវការរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) និងឯកសារដើមជាភាសាអង់គ្លេសនៃឯកសារនេះគឺជាអត្ថបទត្រឹមត្រូវតែមួយគត់ (មានន័យថា ជាឯកសារផ្លូវការនិងអាចយកជាការបាន)។ ការស្រង់ចេញនានាត្រូវតែយោងទៅលើឯកសារដើមជាភាសាអង់គ្លេស ។

# ធនាគារអភិវឌ្ឍន៍អាស៊ី

# គោលការណ៍ណែនាំ
# សំរាប់លទ្ធកម្ម
# ក្នុងក្របខ័ណ្ឌ
# ឥណទានពី
# ធនាគារអភិវឌ្ឍន៍អាស៊ី

ប្រើប្រាស់សំរាប់គំរោងឥណទានផ្តល់ដោយ
ធនាគារអភិវឌ្ឍន៍អាស៊ី
បានពីធនធានទុនទូទៅ និងធនធានមូលនិធិពិសេស

ធនាគារអភិវឌ្ឍន៍អាស៊ី

ខែកុម្ភៈ ឆ្នាំ ១៩៩៩

# គោលការណ៍ណែនាំ
# សំរាប់លទ្ធកម្ម
# ក្នុងក្របខ័ណ្ឌ
# ឥណទានពី
# ធនាគារអភិវឌ្ឍន៍អាស៊ី

អនុវត្តសំរាប់គំរោងឥណទានផ្តល់ដោយ

ធនាគារអភិវឌ្ឍន៍អាស៊ី

បានពីធនធានទុនទូទៅ និងធនធានមូលនិធិពិសេស

ខែកុម្ភៈ ឆ្នាំ ១៩៩៩

## មាតិកាអត្ថបទ

**ទំព័រ**


I. **សេចក្តីផ្តើម**...1

ក. គោលបំណង...1

ខ. លក្ខខណ្ឌទូទៅ...1

គ. ការប្រើប្រាស់គោលការណ៍ណែនាំនេះ...2

ឃ. អំពើគៃបន្លំ និងអំពើពុករលួយ...3

II. **ការដេញថ្លៃជាលក្ខណៈប្រកួតប្រជែងអន្តរជាតិ**...5

ក. លក្ខណៈទូទៅ...5

ប្រភេទ និងទំហំនៃកិច្ចសន្យា...5

ការផ្សាយពត៌មាន និងការជូនដំណឹង...6

ការវាយតំលៃជាបឋមលើលក្ខណៈសម្បត្តិ
របស់ក្រុមហ៊ុនសុំចូលដេញថ្លៃ...7

ចំណាត់ការមុនពេលធ្វើលទ្ធកម្ម...7

ខ. ឯកសារដេញថ្លៃ...8

លក្ខណៈទូទៅ...8

សេចក្តីយោងចំពោះធនាគារអភិវឌ្ឍន៍អាស៊ី...9

ភាសា...9

ភាពច្បាស់លាស់នៃឯកសារដេញថ្លៃ...9

ប្រាក់កក់ដេញថ្លៃ...10

លក្ខខណ្ឌនៃកិច្ចសន្យា...10

បទដ្ឋាន...11

ការប្រើប្រាស់ឈ្មោះពាណិជ្ជកម្ម...11

ប្រភពនៃលទ្ធកម្ម...11

ការកំនត់ថ្លៃ...12

ខស្តីពីរូបិយវត្ថុ...13

រូបិយវត្ថុប្រើក្នុងការដេញថ្លៃ...13

រូបិយវត្ថុសំរាប់ប្រៀបធៀបសំណើដេញថ្លៃ...13

រូបិយវត្ថុសំរាប់ទូទាត់ និងការ
ប្រថុយប្រថាននៃការប្តូរប្រាក់.....................................14
លក្ខខណ្ឌ និងរបៀបទូទាត់........................................15
ខស្តីពីការកែតំរូវថ្លៃ..................................................15
ការទូទាត់ជាមុន.....................................................15
ប្រាក់កក់សំរាប់ការអនុវត្តន៍ និងប្រាក់រក្សាទុក.................16
ការធានារ៉ាប់រង និងការដឹកជញ្ជូន...............................16
សំណងព្រាងទុក ...................................................16
ប្រធានសក្តិ.........................................................17
ការដោះស្រាយទំនាស់.............................................17
គ. ការបើកសំណើដេញថ្លៃ ការវាយតំលៃ
សំណើដេញថ្លៃ និងការផ្តល់កិច្ចសន្យា..........................18
ចន្លោះពេលរវាងការអញ្ជើញ និងការដាក់សំណើដេញថ្លៃ..18
នីតិវិធីបើកសំណើដេញថ្លៃ .......................................18
ការពន្យារពេលសុពលភាពនៃសំណើដេញថ្លៃ .................19
ការបំភ្លឺ ឬការកែប្រែសំណើដេញថ្លៃ ............................19
ការសំងាត់នៃនីតិវិធី................................................19
ការពិនិត្យសំណើដេញថ្លៃ..........................................19
ការវាយតំលៃ និងការប្រៀបធៀបសំណើដេញថ្លៃ............20
នីតិវិធីដេញថ្លៃជាពីរដំណាក់កាល...............................21
ការបដិសេធសំណើដេញថ្លៃទាំងអស់
និងការដេញថ្លៃឡើងវិញ..........................................22
ការផ្តល់កិច្ចសន្យា...................................................23
III. **ប្រភេទផ្សេងទៀតនៃលទ្ធកម្ម** .......................................23
ក. សេចក្តីផ្តើម .........................................................23
ខ. ការជាវទំនិញជាអន្តរជាតិ.........................................24
គ. ការដេញថ្លៃជាលក្ខណៈប្រកួតប្រជែងក្នុងស្រុក................24
ឃ. ការជាវដោយផ្ទាល់/ការចរចា ឬអ្នកដេញថ្លៃតែមួយ..........25
ង. ការដេញថ្លៃមានកំរិត ឬការជាវទំនិញដដែលៗ................26

ច. គណនីដែលមានពិត ................................................26
ឆ. ការជាវបរិក្ខារដោយអ្នកខ្ចីបន្តឯកជនខ្នាតតូច..................27
ជ. លទ្ធកម្មក្រុបខ័ណ្ឌឥណទានសំរាប់ស្ថាប័ន
ផ្តល់ហិរញ្ញវត្ថុដើម្បីការអភិវឌ្ឍន៍.................................27
ឈ. លទ្ធកម្មក្រុបខ័ណ្ឌឥណទានឯកជន
ដោយគ្មានការធានាពីរដ្ឋាភិបាល.................................28
ញ. លទ្ធកម្មក្រុបខ័ណ្ឌនៃការផ្តល់ហិរញ្ញវត្ថុបន្ថែម និង
ក្រោមឥណទានធានាដោយធនាគារអភិវឌ្ឍន៍អាស៊ី..........29
ដ. ការចូលរួមរបស់សហគមន៍ក្នុងលទ្ធកម្ម.........................29
IV. **ការពិនិត្យអំពីសកម្មភាពលទ្ធកម្មរបស់ភាគីខ្ចីឥណទាន**.......30
ក. ការរៀបចំកញ្ចប់សំណើដេញថ្លៃ .................................30
ខ. នីតិវិធីវាយតំលៃជាបឋមលើលក្ខណៈសម្បត្តិ...................30
គ. លទ្ធកម្មមានលក្ខណៈប្រកួតប្រជែងជាអន្តរជាតិ...............31

# I. សេចក្តីផ្តើម

## ក. គោលបំណង

1.01 គោលការណ៍ណែនាំនេះ មានបំណងជូនដំណឹងដល់បណ្តាភាគីខ្ចីឥណទាន [1] ពីធនាគារអភិវឌ្ឍន៍អាស៊ី និងបណ្តាភាគីផ្គត់ផ្គង់ ក៏ដូចជាភាគីម៉ៅការ អំពីគោលការណ៍ទូទៅ និងនីតិវិធី ដែលត្រូវប្រកាន់យក សំរាប់ការធ្វើលទ្ធកម្មការផ្គត់ផ្គង់ទំនិញ និងសេវាកម្មការងារ [2] ដែលផ្តល់ហិរញ្ញវត្ថុដោយធនាគារអភិវឌ្ឍន៍អាស៊ី ។ ករណីផ្ទុយពីនេះអាចប្រព្រឹត្តទៅបាន លុះត្រាតែមានការឯកភាពពីធនាគារអភិវឌ្ឍន៍អាស៊ីជាមុន ។ គោលការណ៍នេះសំរាប់អនុវត្តក្នុងលទ្ធកម្មដែលប្រើប្រាស់ប្រាក់កម្ចី ក្នុងក្របខ័ណ្ឌធនធានទុនទូទៅ និងធនធានមូលនិធិពិសេសពីធនាគារអភិវឌ្ឍន៍អាស៊ី លើកលែងតែលទ្ធកម្មនោះប្រព្រឹត្តទៅក្នុងក្របខ័ណ្ឌនៃធនធានមូលនិធិពិសេស សំរាប់បណ្តាប្រទេសជឿនលឿនមួយចំនួន ដែលបានរួមចំណែកផ្តល់ធនធានទាំងនោះ និងចំពោះគ្រប់បណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដែលជាសមាជិក ។

1.02 ធនាគារអភិវឌ្ឍន៍អាស៊ី និងភាគីខ្ចីមូលនិធិ អាចឯកភាពគ្នាលើរបៀបចាត់ចែងបន្ថែមណាមួយ ទាក់ទងនឹងការចំណាយប្រាក់ឥណទាន តាមករណីដោយឡែកនីមួយៗនៃកិច្ចព្រមព្រៀងស្តីពីការខ្ចីឥណទាន ។ ទំនាក់ទំនងរវាងភាគីខ្ចីឥណទាន និងអ្នកផ្គត់ផ្គង់ទំនិញ ឬអ្នកផ្តល់សេវាកម្មការងារ ត្រូវធ្វើឡើង យោងតាមឯកសារដេញថ្លៃ ដែលចេញដោយភាគីខ្ចីឥណទាន និងកិច្ចសន្យារវាងភាគីខ្ចីឥណទាន និងអ្នកផ្គត់ផ្គង់ ដែលនឹងត្រូវរៀបចំជាមុន ដោយអនុលោមតាមគោលការណ៍នេះ និងកិច្ចព្រមព្រៀងខ្ចីឥណទាន ។

## ខ. លក្ខខណ្ឌទូទៅ

1.03 ទោះបីភាគីខ្ចីឥណទានជាអ្នកទទួលខុសត្រូវសំខាន់ ក្នុងការធ្វើលទ្ធកម្មផ្គត់ផ្គង់ទំនិញ និងសេវាកម្មការងារ សំរាប់គំរោងក្តី ក៏ធនាគារអភិវឌ្ឍន៍អាស៊ីមានកាតព្វកិច្ចដើម្បីធានាថា ប្រាក់កម្ចីពីធនាគារត្រូវប្រើប្រាស់ ប្រកបដោយការប្រុងប្រយ័ត្ន ទាំងផ្នែកប្រសិទ្ធភាព ទាំងផ្នែកសេដ្ឋកិច្ច ។ ក្នុងន័យនេះ ធនាគារអភិវឌ្ឍន៍អាស៊ីមានគោលការណ៍សំខាន់ចំនួនបួន សំរាប់ទ្រទ្រង់លទ្ធកម្មក្រោមប្រាក់កម្ចីរបស់ធនាគារ :

(ក) យោងតាមលក្ខខណ្ឌដូចមានចែងក្នុងកថាខ័ណ្ឌ 1.01 ស្តីពីលទ្ធកម្មក្រោមគំរោងឥណទានក្នុងក្របខ័ណ្ឌធនធានមូលនិធិពិសេស ការ

---

[1] ពាក្យថា"ភាគីខ្ចីឥណទាន" ដែលមានប្រើប្រាស់ក្នុងឯកសារនេះមានន័យថា ជាស្ថាប័នប្រតិបត្តិគំរោង ។

[2] ចំពោះការជ្រើសរើស ឬទទួលយកទីប្រឹក្សា សូមអាន *គោលការណ៍ណែនាំស្តីពីការប្រើប្រាស់ទីប្រឹក្សា* ដោយធនាគារអភិវឌ្ឍន៍អាស៊ី និងភាគីខ្ចីឥណទាន ។

ចំណាយប្រាក់កម្ចីអាចធ្វើទៅបាន សំរាប់តែលទ្ធកម្មផ្គត់ផ្គង់ទំនិញ និងសេវាកម្មការងារ ដែលផលិត និងមានប្រភពពីបណ្តាប្រទេសជាសមាជិកនៃធនាគារអភិវឌ្ឍន៍អាស៊ី លើកលែងតែក្នុងករណីដែលមានការសំរេចពីក្រុមប្រឹក្សាភិបាល ដូចមានចែងក្នុងមាត្រា 14(ix) នៃបណ្តាមាត្រាក្នុងកិច្ចព្រមព្រៀងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ។

(ខ) ដើម្បីជួយបង្កើនប្រសិទ្ធិភាពសេដ្ឋកិច្ច និងសមិទ្ធិផលនៃលទ្ធកម្ម ធនាគារអភិវឌ្ឍន៍អាស៊ីតំរូវឱ្យអ្នកខ្ចីឥណទានទទួលជាវទំនិញ និងសេវាកម្មការងារ ដោយមានការប្រកួតប្រជែងជាអន្តរជាតិ លើកលែងតែក្នុងកាលៈទេសៈពិសេស ដែលមានការឯកភាពរវាងធនាគារអភិវឌ្ឍន៍អាស៊ី និងភាគីខ្ចីឥណទាន ឱ្យប្រើប្រាស់នីតិវិធីផ្សេង ដែលល្អប្រសើរជាង ។

(គ) ក្នុងនាមជាស្ថាប័នសហប្រតិបត្តិការអន្តរជាតិមួយ ធនាគារអភិវឌ្ឍន៍អាស៊ី ផ្តល់ឱកាសដល់គ្រប់ប្រទេសជាសមាជិក ក្នុងការផ្គត់ផ្គង់ទំនិញ និងសេវាកម្មការងារ ក្នុងក្របខ័ណ្ឌហិរញ្ញវត្ថុដែលផ្តល់ដោយធនាគារអភិវឌ្ឍន៍អាស៊ី ។

(ឃ) តំលាភាពមានសារៈសំខាន់ណាស់នៅក្នុងដំនើរលទ្ធកម្ម ដើម្បីសំរេចឱ្យបានសមិទ្ធិផល និងប្រសិទ្ធិភាពសេដ្ឋកិច្ចខ្ពស់ និងដើម្បីប្រឆាំងអំពើគៃបន្លំ និងអំពើពុករលួយ ។

## គ. ការប្រើប្រាស់គោលការណ៍ណែនាំនេះ

1.04 ក្នុងករណីដែលគំរោងមួយពាក់ព័ន្ធនឹងកិច្ចសន្យាច្រើន ហើយការអនុវត្តន៍កិច្ចសន្យាមួយចំនួននឹងមិនពាក់ព័ន្ធនឹងការចំណាយប្រាក់កម្ចីពីធនាគារអភិវឌ្ឍន៍អាស៊ីទេ នោះអ្នកខ្ចីឥណទានអាចប្រកាន់យកនីតិវិធីលទ្ធកម្មរបស់ខ្លួនផ្ទាល់ខ្លួន សំរាប់កិច្ចសន្យាទាំងនេះ តែភាគីខ្ចីឥនទានត្រូវធានាដល់ធនាគារថានីតិវិធីទាំងនោះ នឹងអាចឱ្យខ្លួនបំពេញកាតព្វកិច្ចទូទៅក្នុងការអនុវត្តន៍គំរោងប្រកបដោយប្រសិទ្ធិភាព ការប្រុងប្រយ័ត្ន និងស្របតាមលក្ខណៈវិស្វកម្ម និងទំលាប់ប្រតិបត្តិសមស្របនានា ។ ផ្ទុយទៅវិញ ភាគីខ្ចីឥណទានត្រូវគោរពតាមគោលការណ៍ណែនាំរបស់ធនាគារអភិវឌ្ឍន៍អាស៊ីស្តីពីលទ្ធកម្ម នៅពេលអនុវត្តកិច្ចសន្យាណា ដែលប្រើប្រាស់មូលនិធិកម្ចី ទោះបីមូលនិធិនោះត្រូវប្រើប្រាស់សំរាប់ទ្រទ្រង់ចំណែកណាមួយនៃកិច្ចសន្យា ឬសំរាប់ទ្រទ្រង់ការអនុវត្តន៍កិច្ចសន្យានោះទាំងមូលក្តី ។

1.05 នីតិវិធីសំរាប់អនុវត្ត ដើម្បីធានាឱ្យមានការដេញថ្លៃប្រកួតប្រជែងជាអន្តរជាតិដោយប្រសិទ្ធិភាព មានចែងក្នុងជំពូក II និង IV នៃគោលការណ៍ណែនាំនេះ ។ ជំពូក III ចែងពីកាលៈទេសៈដែលអនុញ្ញាតឱ្យប្រើប្រាស់វិធីសាស្ត្រផ្សេងពីការដេញថ្លៃប្រកួតប្រជែងជាអន្តរជាតិ ដើម្បីធានាឱ្យមានផល

ប្រយោជន៍ខាងផ្នែកសេដ្ឋកិច្ច និងប្រសិទ្ធិភាព ។ ជាទូទៅ ការប្រើប្រាស់វិធីណាមួយខាងលើនឹងមានចែងជាលាយលក្ខណ៍អក្សរ ក្នុងកិច្ចព្រមព្រៀងខ្ចីឥណទានសំរាប់គំរោងនីមួយៗ ។

## ឃ. អំពើគៃបន្លំ និងអំពើពុករលួយ

1.06 គោលនយោបាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី តំរូវឱ្យភាគីខ្ចីឥណទាន (រួមទាំងអ្នកទទួលផលពីប្រាក់កម្ចីពីធនាគារអភិវឌ្ឍន៍អាស៊ី) ក៏ដូចជាអ្នកចូលដេញថ្លៃ/អ្នកផ្គត់ផ្គង់/ភាគីម៉ៅការ ក្នុងក្របខ័ណ្ឌនៃកិច្ចសន្យាផ្តល់ហិរញ្ញវត្ថុដោយធនាគារអភិវឌ្ឍន៍អាស៊ី គោរពឱ្យបានត្រឹមត្រូវតាមបទដ្ឋាននៃក្រមសីលធម៌ ក្នុងពេលធ្វើលទ្ធកម្ម និងពេលអនុវត្តកិច្ចសន្យាទាំងនោះ ។ អនុលោមតាមគោលនយោបាយនេះ ធនាគារអភិវឌ្ឍន៍អាស៊ី :

(ក) កំនត់និយមន័យដូចខាងក្រោម :

(i) "ការប្រព្រឹត្តអំពើពុករលួយ" មានន័យថា ជាឥរិយាបទនៃមន្ត្រីនៅក្នុងស្ថាប័នសាធារណៈ ឬស្ថាប័នឯកជន ដែលប្រព្រឹត្តមិនត្រឹមត្រូវ និងខុសច្បាប់ ដើម្បីទាញយកនូវប្រយោជន៍ផ្ទាល់ខ្លួន និង/ឬសំរាប់មនុស្សជិតស្និទ្ធ ឬអន្ទងអ្នកដទៃឱ្យប្រព្រឹត្តដូចនេះ ដោយប្រើប្រាស់ឋានៈរបស់ខ្លួនពុំត្រឹមត្រូវ ហើយអំពើទាំងនោះរួមមាន ជំនូន ការផ្តល់ឱ្យ ការទទួល ឬការសុំអ្វីម៉្យាងដែលមានតំលៃ សំដៅដាក់ឥទ្ធិពលទៅលើសកម្មភាពរបស់មន្ត្រីទាំងនោះ នៅក្នុងដំណើរការលទ្ធកម្ម ឬនៅក្នុងអំឡុងពេលនៃការអនុវត្តន៍កិច្ចសន្យា ។

(ii) "ការប្រព្រឹត្តអំពើគៃបន្លំ" មានន័យថា ជាការកុហកបំភ្លៃខុសពីការពិតជាក់ស្តែង ដើម្បីជំរុញឱ្យដំនើរការលទ្ធកម្ម ឬការអនុវត្តន៍កិច្ចសន្យា បង្កនូវការខូចខាតដល់ភាគីខ្ចីឥណទាន ហើយរួមមាន ការស៊ុំគ្រលំរវាងអ្នកចូលរួមដេញថ្លៃ (មុន ឬក្រោយពេលដាក់ពាក្យសុំដេញថ្លៃ) ក្នុងគោលបំនងបង្កើតតំលៃនៃការដេញថ្លៃក្លែងក្លាយ ដោយពុំមានការប្រកួតប្រជែងពិតប្រាកដ និងធ្វើឱ្យភាគីខ្ចីឥណទានបាត់បង់ផលប្រយោជន៍ ដោយសារពុំមានការប្រកួតប្រជែងដោយសេរី និងចំហ ។

(ខ) នឹងបដិសេធសំនើផ្តល់កិច្ចសន្យា ប្រសិនបើធនាគារអភិវឌ្ឍន៍អាស៊ីរកឃើញថា ក្រុមហ៊ុនដេញថ្លៃដែលបានស្នើឱ្យផ្តល់កិច្ចសន្យា មាន

ការពាក់ព័ន្ធក្នុងអំពើពុករលួយ ឬការគៃបន្លំនៅក្នុងការប្រកួតប្រជែងដេញថ្លៃ ។

(គ) នឹងលុបចោលផ្នែកណាមួយនៃគំរោងឥណទាន ដែលបំរុងទុកសំរាប់ចុះកិច្ចសន្យាផ្គត់ផ្គង់ទំនិញ ឬសេវាកម្មការងារ ប្រសិនបើនៅពេលណាមួយ ធនាគារអភិវឌ្ឍន៍អាស៊ីរកឃើញថា អំពើពុករលួយ ឬអំពើគៃបន្លំត្រូវបានប្រព្រឹត្តដោយបណ្តាអ្នកជាតំណាងភាគីខ្ចីឥណទាន ឬដោយបណ្តាក្រុមអ្នកទទួលប្រយោជន៍ពីប្រាក់កម្ចីនេះ នៅក្នុងដំណើរការលទ្ធកម្ម ឬការប្រតិបត្តិកិច្ចសន្យា ហើយភាគីខ្ចីឥណទានពុំបានចាត់វិធានការទាន់ពេលវេលា និងសមស្រប ដែលធនាគារអភិវឌ្ឍន៍អាស៊ីអាចទទួលយកបាន ក្នុងការស្តារសភាពការណ៍នោះ ។

(ឃ) នឹងប្រកាសយ៉ាងដាច់អហង្ការនូវការដកហូតសិទ្ធិជារៀងរហូត ឬសំរាប់ចន្លោះពេលណាមួយជាកំនត់ ពីក្រុមហ៊ុនណាមួយ មិនឱ្យទទួលកិច្ចសន្យា ដែលផ្តល់ហិរញ្ញវត្ថុដោយធនាគារអភិវឌ្ឍន៍អាស៊ី ប្រសិនបើនៅពេលណាមួយ ធនាគារអភិវឌ្ឍន៍អាស៊ីរកឃើញថា ក្រុមហ៊ុននោះបានពាក់ព័ន្ធនឹងការប្រព្រឹត្តអំពើពុករលួយ ឬគៃបន្លំក្នុងការប្រកួតប្រជែងដេញថ្លៃ ឬក្នុងការអនុវត្តន៍កិច្ចសន្យា ដែលផ្តល់ហិរញ្ញវត្ថុដោយធនាគារអភិវឌ្ឍន៍អាស៊ី ។ និង

(ង) នឹងមានសិទ្ធិដាក់កំហិត នៅក្នុងកិច្ចសន្យាដែលផ្តល់ហិរញ្ញវត្ថុដោយប្រាក់កម្ចីពីធនាគារអភិវឌ្ឍន៍អាស៊ី នូវខដែលចែងពីកាតព្វកិច្ចឱ្យអ្នកផ្គត់ផ្គង់ និងភាគីម៉ៅការ អនុញ្ញាតឱ្យធនាគារអភិវឌ្ឍន៍អាស៊ីធ្វើអធិការកិច្ចលើបញ្ជីគណនេយ្យ និងរាល់បញ្ជីកំនត់ហេតុរបស់ខ្លួន ទាក់ទងនឹងការអនុវត្តន៍កិច្ចសន្យា និងធ្វើសវនកម្មលើបញ្ជីទាំងនោះដោយសវនករ ដែលជ្រើសរើសដោយធនាគារអភិវឌ្ឍន៍អាស៊ី ។

1.07 ចំពោះកិច្ចសន្យា ដែលផ្តល់ហិរញ្ញវត្ថុជាទ្រង់ទ្រាយធំដោយធនាគារអភិវឌ្ឍន៍អាស៊ី និងដោយមានកិច្ចព្រមព្រៀងជាពិសេសជាមួយធនាគារអភិវឌ្ឍន៍អាស៊ី នៅក្នុងការប្រកួតប្រជែងយកសិទ្ធិអនុវត្តកិច្ចសន្យា ភាគីខ្ចីឥណទានអាចដាក់បញ្ចូលទៅក្នុងពាក្យសុំដេញថ្លៃនូវលក្ខខណ្ឌ ឱ្យអ្នកចូលដេញថ្លៃគោរពតាមបណ្តាច្បាប់ក្នុងស្រុកប្រឆាំងនឹងអំពើគៃបន្លំ និងអំពើពុករលួយ (រួមទាំងការស៊ីសំណូក) ដូចដែលមានចែងនៅក្នុងឯកសារដាក់ដេញថ្លៃ ។ លេខយោងសំគាល់មួយនឹងត្រូវដាក់នៅក្នុងឯកសារដេញថ្លៃ ដោយបញ្ជាក់ថាលក្ខខណ្ឌទាំងនេះ ត្រូវបានដាក់បញ្ចូលតាមសំណើរបស់ភាគីខ្ចីឥណទាន ។

1.08 ក្នុងករណីដែលកិច្ចសន្យាត្រូវផ្តល់ហិរញ្ញវត្ថុដោយធនាគារអភិវឌ្ឍន៍អាស៊ីទាំងស្រុង ឬដោយផ្នែក នៅក្នុងឯកសារកិច្ចសន្យាត្រូវមានដាក់បញ្ចូលការ

សន្យាដោយភាគីម៉ៅការថា ពុំមានខ្ទង់ចំណាយជាប្រាក់កំរៃ ប្រាក់ទឹកតែ ការបង្វិលប្រាក់សង អំណោយ កំរៃជើងសារ ឬការចំណាយណាផ្សេងទៀត ដែលពុំមានចែងក្នុងឯកសារដេញថ្លៃ នឹងត្រូវផ្តល់ឱ្យ ឬទទួលយក ពាក់ព័ន្ធជាមួយដំណើរការដេញថ្លៃ ឬក្នុងការអនុវត្តន៍កិច្ចសន្យាឡើយ ។

## II. ការដេញថ្លៃជាលក្ខណៈប្រកួតប្រជែងអន្តរជាតិ

### ក. លក្ខណៈទូទៅ

2.01 គោលបំណងនៃការដេញថ្លៃជាលក្ខណៈប្រកួតប្រជែងអន្តរជាតិ គឺដើម្បីផ្តល់ឱ្យភាគីខ្ចីឥណទាន នូវជំរើសជាច្រើន ក្នុងការជ្រើសរើសយកសំណើដេញថ្លៃណាមួយ ដែលល្អប្រសើរជាងគេបំផុត ក្នុងចំណោមក្រុមហ៊ុនផ្គត់ផ្គង់/ភាគីម៉ៅការ ក៏ដូចជាដើម្បីផ្តល់នូវឱកាសនៃការប្រកួតប្រជែងដោយយុត្តិធម៌ និងស្មើភាព សំរាប់ការដេញថ្លៃទទួលយកកិច្ចសន្យាផ្គត់ផ្គង់ទំនិញ និងសេវាកម្មការងារ ក្នុងក្របខ័ណ្ឌឥណទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ជូនដល់ក្រុមហ៊ុនសុំចូលដេញថ្លៃដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មកពីប្រទេសផ្តល់ទុននានាដែលមានសិទ្ធិចូលរួម ។ ដើម្បីសំរេចគោលបំណងបែបនេះបាន ធនាគារអភិវឌ្ឍន៍អាស៊ីតំរូវឱ្យភាគីខ្ចីឥណទានរបស់ខ្លួន គោរពតាមគោលការណ៍ណែនាំមួយចំនួន ក្នុងការរៀបចំឯកសារដេញថ្លៃ និងឯកសារកិច្ចសន្យា ហើយត្រូវអនុវត្តតាមនីតិវិធីមួយចំនួន ក្នុងការផ្តល់ពត៌មានអញ្ជើញក្រុមហ៊ុននានាឱ្យចូលដេញថ្លៃ និងក្នុងការទទួលយក ការបើក និងការវាយតំលៃសំណើដេញថ្លៃ ។ លើសពីនេះ សេចក្តីព្រាងឯកសារដេញថ្លៃ របាយការណ៍វាយតំលៃសំណើដេញថ្លៃ និងសំនើផ្តល់កិច្ចសន្យាទៅក្រុមហ៊ុនណាមួយ ត្រូវឆ្លងកាត់ការពិនិត្យ និងឯកភាពជាមុនពីធនាគារអភិវឌ្ឍន៍អាស៊ី ដូចមានចែងក្នុងជំពូក IV នៃគោលការណ៍ណែនាំនេះ ។

### ប្រភេទ និងទំហំនៃកិច្ចសន្យា

2.02 កិច្ចសន្យាអាចនឹងផ្តល់បាន ដោយផ្អែកលើថ្លៃឯកតាជាមូលដ្ឋាន (សំរាប់សេវាកម្មការងារ ឬទំនិញដែលត្រូវផ្គត់ផ្គង់) ឬផ្អែកលើថ្លៃសរុប ឬផ្អែកលើកត្តាទាំងពីររួមគ្នា សំរាប់ចំណែកផ្សេងៗនៃកិច្ចសន្យា ដោយអាស្រ័យតាមប្រភេទទំនិញ ឬសេវាកម្មការងារពាក់ព័ន្ធ ។ លក្ខខណ្ឌនៃការផ្តល់កិច្ចសន្យានឹងមានចែងនៅក្នុងឯកសារដេញថ្លៃជាមុន ។

2.03 តាមលទ្ធភាពដែលអាចធ្វើបាន លទ្ធកម្មត្រូវតែប្រព្រឹត្តទៅតាមបែប ដែលកញ្ចប់ដេញថ្លៃ ឬកិច្ចសន្យាត្រូវមានទំហំគ្រប់គ្រាន់ សំរាប់ទាក់ទាញឱ្យមានការប្រកួតប្រជែងជាអន្តរជាតិ ។ ទំហំ និងវិសាលភាពនៃកិច្ចសន្យានីមួយៗ ប្រែប្រួលអាស្រ័យទៅតាមទំហំ ប្រភេទ និងទីតាំងនៃគំរោង ។

2.04 ចំពោះគំរោងដែលតំរូវឱ្យមានការងារផ្គត់ផ្គង់ ការងារសាងសង់ និងការតំឡើងបរិក្ខារផងនោះ ជាធម្មតាត្រូវមានការបំបែកកិច្ចសន្យាបែបនេះជាផ្នែកផ្សេងៗពីគ្នា ។ ក្នុងករណីដែលមានការងារសាងសង់ ឬប្រភេទសំភារៈមួយចំនួនប្រហាក់ប្រហែលគ្នា តែនៅដោយឡែកពីគ្នា នោះការដេញថ្លៃនឹងត្រូវធ្វើក្រោមជំរើសផ្សេងៗគ្នានៃកិច្ចសន្យា ដែលក្នុងនោះ អ្នកផ្គត់ផ្គង់ ឬភាគីម៉ៅការ ទោះបីធំឬតូចក្តី ត្រូវអនុញ្ញាតឱ្យចូលរួមដេញថ្លៃសំរាប់កិច្ចសន្យានីមួយៗ ឬសំរាប់កិច្ចសន្យាប្រហាក់ប្រហែលគ្នាមួយចំនួន ទៅតាមការជ្រើសរើសរបស់ពួកគេ ហើយគ្រប់សំណើដេញថ្លៃនីមួយៗ និងសំណើដេញថ្លៃរួមគ្នា នឹងត្រូវទទួលការវាយតំលៃក្នុងពេលតែមួយ ដើម្បីពិនិត្យមើលថា ក្នុងចំណោមសំណើដេញថ្លៃនីមួយៗ និងសំណើដេញថ្លៃរួមគ្នា តើជំរើសណាមួយដែលប្រសើរជាងគេ ។

2.05 ក្នុងករណីសមស្រប ឧទាហរណ៏ក្នុងករណីពាក់ព័ន្ធនឹងដំណើរការពិសេស ឬករណីពាក់ព័ន្ធនឹងផលិតកម្មចំរុះដែលផ្នែកផ្សេងៗមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ ធនាគារអភិវឌ្ឍន៏អាស៊ីអាចអនុញ្ញាតឱ្យមានកិច្ចសន្យាសោក្នុងដៃ ដែលក្នុងនោះ ការងារវិស្វកម្ម ការផ្គត់ផ្គង់សំភារៈ និងការសាងសង់រោងចក្រទាំងមូល ត្រូវប្រព្រឹត្តទៅតាមរយៈកិច្ចសន្យាតែមួយ ។ ក្នុងករណីកិច្ចសន្យាសោក្នុងដៃ ឬកិច្ចសន្យាសំរាប់គំរោងការឧស្សាហកម្មទ្រង់ទ្រាយធំ គេគួរតែអនុវត្តនីតិវិធីដេញថ្លៃជាពីរដំណាក់កាល (មើលកថាខ័ណ្ឌ 2.47) ។

## ការផ្សាយព័តមាន និងការជូនដំណឹង

2.06 គ្រប់ប្រទេសជាសមាជិកនៃធនាគារអភិវឌ្ឍន៏អាស៊ី ដែលមានសិទ្ធិចូលរួម នឹងត្រូវទទួលសេចក្តីជូនដំណឹងយ៉ាងសមស្រប អំពីឱកាសនៃការដេញថ្លៃ ។ សេចក្តីអញ្ជើញចូលរួមធ្វើការដេញថ្លៃ នឹងត្រូវមានផ្សព្វផ្សាយជូននៅក្នុងសាពតិមានរបស់ធនាគារ "ឱកាសក្នុងមុខជំនួញជាមួយធនាគារអភិវឌ្ឍន៏អាស៊ី" ក៏ដូចជានៅក្នុងព្រឹត្តិប័ត្រពតិមាន ដែលចែកជូនជាទូទៅនៅក្នុងបណ្តាប្រទេសជាអ្នកខ្ចីឥណទាន (យ៉ាងហោចណាស់មានជាភាសាអង់គ្លេស) ។ សេចក្តីអញ្ជើញចូលរួមដេញថ្លៃមួយច្បាប់ត្រូវផ្ញើជូនទៅធនាគារអភិវឌ្ឍន៏អាស៊ី ដើម្បីសុំការឯកភាព និងសំរាប់បោះពុម្ពផ្សាយក្នុងព្រឹត្តិប័ត្រសារពិតមាន "ឱកាសក្នុងមុខជំនួញជាមួយធនាគារអភិវឌ្ឍន៏អាស៊ី" ដោយអនុលោមតាមបណ្តាខ ដែលមានចែងក្នុងកិច្ចព្រមព្រៀងខ្ចីឥណទាន ។

2.07 ចំពោះកិច្ចសន្យាទ្រង់ទ្រាយធំ ឬកិច្ចសន្យាពិសេស ធនាគារអភិវឌ្ឍន៏អាស៊ីអាចទាមទារបន្ថែម ឱ្យចុះផ្សាយសេចក្តីអញ្ជើញចូលរួមដេញថ្លៃ និង/ឬសេចក្តីជូនដំណឹងស្តីពីលទ្ធកម្ម នៅក្នុងសារពតិមានបច្ចេកទេស ឬក្នុងសារពតិមានពាណិជ្ជកម្មល្បីៗ ឬក្នុងសារពតិមានដែលមានការចែកផ្សាយទូលំទូលាយជាអន្តរជាតិជាមុន ដើម្បីឱ្យក្រុមហ៊ុនដេញថ្លៃនានាមានពេលគ្រប់គ្រាន់សំរាប់រៀបចំ និងដាក់ពាក្យសុំដេញថ្លៃ ។

## ការវាយតំលៃជាបឋមលើលក្ខណៈសម្បត្តិរបស់ក្រុមហ៊ុនសុំចូលដេញថ្លៃ

2.08 ដើម្បីធានាថា មានតែក្រុមហ៊ុនដែលមានសមត្ថភាព ទាំងខាងបច្ចេកទេស ទាំងខាងហិរញ្ញវត្ថុប៉ុណ្ណោះ នឹងត្រូវអញ្ជើញឱ្យចូលរួមដេញថ្លៃ ចាំបាច់ត្រូវធ្វើការវាយតំលៃជាបឋមលើលក្ខណៈសម្បត្តិរបស់ក្រុមហ៊ុន ដែលសុំចូលដេញថ្លៃ ហើយការវាយតំលៃនេះត្រូវធ្វើឡើង សំរាប់ភាគច្រើននៃកិច្ចសន្យាការងារស៊ីវិល កិច្ចសន្យាសោក្នុងដៃ និងកិច្ចសន្យាផ្គត់ផ្គង់ផ្គង់សំភារៈដែលមានលក្ខណៈបច្ចេកទេសខ្ពស់និងមានតំលៃខ្ពស់ ។ ការវាយតំលៃជាបឋមលើលក្ខណៈសម្បត្តិរបស់ក្រុមហ៊ុន ត្រូវផ្អែកទាំងស្រុងលើសមត្ថភាពរបស់ក្រុមហ៊ុនទាំងនោះ ក្នុងការអនុវត្តន៏គំរោងការឱ្យបានលទ្ធផលជាទីពេញចិត្ត ដោយរួមបញ្ចូល : (i) បទពិសោធន៏ និងស្នាដៃកន្លងមកសមស្រប (ii) សមត្ថភាពបុគ្គលិក សំភារៈ និងរោងចក្រ និង (iii) ស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ។

2.09 សេចក្តីអញ្ជើញចូលរួមវាយតំលៃជាបឋមលើលក្ខណៈសម្បត្តិ ត្រូវផ្សព្វផ្សាយ និងជូនដំណឹង អនុលោមតាមនីតិវិធី ដូចមានចែងក្នុងកថាខ័ណ្ឌ 2.06 និង 2.07 ។ ទំហំការងារ សេចក្តីបញ្ជាក់លក្ខណៈពិសេសសង្ខេប និងសេចក្តីអធិប្បាយច្បាស់លាស់ អំពីតំរូវការខាងផ្នែកលក្ខណៈសម្បត្តិសំរាប់ការវាយតំលៃជាបឋម នឹងត្រូវផ្ញើជូនទៅគ្រប់ក្រុមហ៊ុនដែលបង្ហាញចេតនាចង់ចូលរួមទទួលការវាយតំលៃជាបឋមលើលក្ខណៈសម្បត្តិ ។ ជាទូទៅ ត្រូវផ្តល់ពេលយ៉ាងហោចណាស់ 60 ថ្ងៃ សំរាប់ឱ្យក្រុមហ៊ុននានា អាចរៀបចំដាក់ជូនពាក្យសុំសំរាប់ការវាយតំលៃជាបឋមលើលក្ខណៈសម្បត្តិ ។ ចំនួនក្រុមហ៊ុនដាក់ពាក្យសំរាប់ការវាយតំលៃជាបឋមលើលក្ខណៈសម្បត្តិនឹងមិនមានកំនត់ឡើយ ហើយគ្រប់ក្រុមហ៊ុនដែលចាត់ទុកថា មានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តន៏ការងារ អនុលោមតាមលក្ខណៈវិនិច្ឆ័យក្នុងពេលវាយតំលៃជាបឋមលើលក្ខណៈសម្បត្តិ នឹងត្រូវអញ្ជើញឱ្យចូលរួមដាក់ពាក្យសុំដេញថ្លៃ ។

2.10 ក្រោយពេលអ្នកដាក់ពាក្យត្រូវបានជ្រើសរើស តាមការវាយតំលៃជាបឋមលើលក្ខណៈសម្បត្តិរួចមក រាល់លិខិតអញ្ជើញ និងឯកសារដេញថ្លៃត្រូវបញ្ជូនដោយផ្ទាល់ទៅក្រុមហ៊ុនដែលបានជ្រើសរើសទាំងនោះ ។

## ចំណាត់ការមុនពេលធ្វើលទ្ធកម្ម

2.11 ក្នុងករណីដែលពិនិត្យឃើញយ៉ាងច្បាស់ថា ការចុះកិច្ចសន្យាឱ្យបានឆាប់ទាក់ទងនឹងការផ្តល់ទំនិញ និងសេវាកម្មការងារ គឺជាកត្តាចាំបាច់បំផុតដើម្បីឱ្យគំរោងអាចបញ្ចប់ទៅតាមកាលកំនត់ ការចេញលិខិតអញ្ជើញដេញថ្លៃ ឬលិខិតអញ្ជើញចូលរួមវាយតំលៃជាបឋមលើលក្ខណៈសម្បត្តិ អាចនឹងប្រព្រឹត្តទៅបាន មុនការអនុម័តផ្តល់ហិរញ្ញវត្ថុសំរាប់គំរោងការនោះ តែត្រូវមានការឯកភាពជាមុនពីធនាគារអភិវឌ្ឍន៏អាស៊ី ។ ក្នុងករណីបែបនេះ មុនពេលផ្សព្វ

ផ្សាយឯកសារដេញថ្លៃ និងឯកសារទាក់ទងនឹងការវាយតំលៃជាបឋមលើលក្ខណៈសម្បត្តិ ធនាគារអភិវឌ្ឍន៍អាស៊ីតំរូវឱ្យដាក់ជូនសេចក្តីព្រាងឯកសារទាំងនោះ ដើម្បីឱ្យខ្លួនអនុម័តជាមុន បន្ទាប់មកត្រូវធ្វើការផ្សព្វផ្សាយ និងជូនពតិមានស្តីពីការដេញថ្លៃ និងការអញ្ជើញឱ្យដាក់ពាក្យសំរាប់ការវាយតំលៃជាបឋមលើលក្ខណៈសម្បត្តិ ដូចមានចែងក្នុងកថាខ័ណ្ឌ 2.06 និង 2.07 ។ ចំណាត់ការមុនពេលធ្វើលទ្ធកម្មបែបនេះមិនអាចចាត់ទុកថា ធនាគារអភិវឌ្ឍន៍អាស៊ីនឹងអនុម័តឯកភាពលើគំរោងនោះបាននៅឡើយទេ ។

## ខ. ឯកសារដេញថ្លៃ

### លក្ខណៈទូទៅ

2.12 (ក) ឯកសារដេញថ្លៃត្រូវមានចែងពីបណ្តាខ ដែលឆ្លើយតបនឹងការទាមទារនៃគោលការណ៍ណែនាំនេះ ដោយអនុញ្ញាតឱ្យមានការកែប្រែ ឬការឃ្លាតចាកណាមួយ ប្រសិនបើមានការឯកភាពគ្នារវាងធនាគារអភិវឌ្ឍន៍អាស៊ី និងភាគីខ្ចីឥណទាន ។

(ខ) ជាការសំខាន់ ដែលឯកសារដេញថ្លៃត្រូវផ្តល់នូវគ្រប់ពតិមានចាំបាច់សំរាប់អ្នកសុំចូលដេញថ្លៃ ដើម្បីរៀបចំសំណើដេញថ្លៃដែលមានលក្ខណៈឆ្លើយតប ។ ទោះបីចំនុចលំអិត និងភាពស៊ាំញ៉ាំនៃឯកសារនេះ មានការប្រែប្រួល អាស្រ័យលើប្រភេទទំនិញ និងទំហំកិច្ចសន្យា ដែលត្រូវធ្វើលទ្ធកម្មក្តី ក៏ឯកសារនេះត្រូវតែមានដាក់បញ្ចូលនូវចំនុចដូចខាងក្រោម : លិខិតអញ្ជើញចូលដេញថ្លៃ សេចក្តីណែនាំសំរាប់ការធ្វើលទ្ធកម្ម ពាក្យសុំចូលដេញថ្លៃ លក្ខខណ្ឌនៃកិច្ចសន្យា (រួមទាំងលក្ខខណ្ឌទូទៅ និងលក្ខខណ្ឌដោយឡែក) សេចក្តីបញ្ជាក់ពីលក្ខណៈបច្ចេកទេស លិខិតបញ្ជាក់បរិមាណនិងរូបគំនូរ តារាងតំលៃ ឯកសារឧបសម្ព័ន្ធចាំបាច់ ប្រាក់កក់ដេញថ្លៃ និងប្រាក់កក់សំរាប់ការអនុវត្តន៍ ។

(គ) ភាគីខ្ចីឥណទានត្រូវប្រើឯកសារដេញថ្លៃគំរូ (Standard Bidding Documents: SBDs) ដែលចេញដោយធនាគារអភិវឌ្ឍន៍អាស៊ី ។ ការកែប្រែ ឬការឃ្លាតចាកខ្លះៗ ខុសពីឯកសារដេញថ្លៃគំរូខាងលើ ដើម្បីធ្វើឱ្យសមស្របតាមស្ថានភាពនៃប្រទេស ឬស្ថានភាពជាក់ស្តែងនៃគំរោង អាចអនុញ្ញាតឱ្យធ្វើតែក្នុងក៏រិតអប្បបរមា និងស្របតាមលក្ខខណ្ឌនៃគោលការណ៍ណែនាំទាំងនេះ ហើយត្រូវមានការឯកភាពពីធនាគារអភិវឌ្ឍន៍អាស៊ី ។ គ្រប់សេចក្តីកែប្រែ ឬការឃ្លាតចាកទាំងនេះអាចត្រូវយកមកប្រើប្រាស់បាន តែតាមរយៈបទបញ្ជាដល់អ្នកសុំចូល

ដេញថ្លៃ និងលក្ខខណ្ឌពិសេសនៃកិច្ចសន្យា/លក្ខខណ្ឌនៃការដាក់ពាក្យសុំជាក់លាក់ណាមួយ ។ ក្នុងករណីដែលធនាគារអភិវឌ្ឍន៍អាស៊ីពុំមានចេញជូន នូវឯកសារដេញថ្លៃគំរូសមស្រប ភាគីខ្ចីឥណទានអាចប្រើឯកសារដេញថ្លៃគំរូផ្សេងទៀត ដែលមានការទទួលស្គាល់ជាអន្តរជាតិ ដោយមានការឯកភាពពីធនាគារអភិវឌ្ឍន៍អាស៊ី និងមានចំនុចស្របគ្នាជាច្រើនជាមួយឯកសារដេញថ្លៃគំរូរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ។

## សេចក្តីយោងចំពោះធនាគារអភិវឌ្ឍន៍អាស៊ី

2.13 ក្នុងករណីដែលកិច្ចសន្យា ត្រូវផ្តល់ហិរញ្ញវត្ថុដោយធនាគារអភិវឌ្ឍន៍អាស៊ី ទោះបីទាំងស្រុងក្តី ឬដោយផ្នែកក្តី គ្រប់ឯកសារដេញថ្លៃត្រូវមានសេចក្តីយោងចំពោះធនាគារអភិវឌ្ឍន៍អាស៊ី ដោយប្រើពាក្យពេចន៍ដូចខាងក្រោម ៖

"...(ឈ្មោះភាគីខ្ចីឥណទាន)... បានទទួលប្រាក់កម្ចីពី (ធនធានទុនទូទៅ ឬធនធានមូលនិធិពិសេស) នៃធនាគារអភិវឌ្ឍន៍អាស៊ី សំរាប់ការចំណាយនៃគំរោង (ឈ្មោះគំរោង) និងសន្យាថា ទឹកប្រាក់បានពីឥណទាននេះនឹងត្រូវយកទៅប្រើប្រាស់ សំរាប់ទូទាត់ចំណាយក្រោម (បណ្តា) កិច្ចសន្យា ដូចមានចែងក្នុងលិខិតអញ្ជើញចូលដេញថ្លៃ ។ ហេតុដូច្នេះ លក្ខខណ្ឌនៃ (បណ្តា) កិច្ចសន្យា និងការទូទាត់ចំណាយដោយធនាគារអភិវឌ្ឍន៍អាស៊ី ត្រូវអនុវត្តទៅតាមលក្ខខណ្ឌនៃកិច្ចព្រមព្រៀងកម្ចីឥណទាន រួមទាំង "គោលការណ៍ណែនាំសំរាប់លទ្ធកម្មក្នុងក្របខ័ណ្ឌឥណទានពីធនាគារអភិវឌ្ឍន៍អាស៊ី" ។ ប្រសិនបើពុំមានការឯកភាពពិសេសពីធនាគារអភិវឌ្ឍន៍អាស៊ីទេ នោះគ្មានភាគីណាមួយក្រៅពី (ឈ្មោះភាគីខ្ចីឥណទាន) អាចនឹងទទួលសិទ្ធិណាមួយពីកិច្ចព្រមព្រៀងកម្ចីឥណទាននេះ ឬមានសិទ្ធិទាមទារប្រើទឹកប្រាក់ពីឥណទាននេះឡើយ ។"

## ភាសា

2.14 យោងតាមបណ្តាមាត្រា នៃកិច្ចព្រមព្រៀងរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ភាសាប្រើប្រាស់ជាផ្លូវការសំរាប់ធនាគារអភិវឌ្ឍន៍អាស៊ីគឺភាសាអង់គ្លេស ហេតុនេះឯកសារដេញថ្លៃ និងបណ្តាឯកសារពាក់ព័ន្ធ រួមទាំងការផ្សព្វផ្សាយពតិមាន ត្រូវធ្វើជាភាសាអង់គ្លេស ។ ក្នុងករណីដែលមានការប្រើប្រាស់ច្រើនភាសា ឯកសារជាភាសាអង់គ្លេសត្រូវមានអធិកភាព ។

## ភាពច្បាស់លាស់នៃឯកសារដេញថ្លៃ

2.15 ដើម្បីលើកទឹកចិត្តឱ្យមានការប្រកួតប្រជែងអន្តរជាតិ ក្នុងការដេញថ្លៃ ឯកសារដេញថ្លៃត្រូវបរិយាយឱ្យបានច្បាស់លាស់ និងត្រឹមត្រូវពីការងារដែលត្រូវអនុវត្ត ឬពីទំនិញដែលត្រូវផ្គត់ផ្គង់ ពីទីកន្លែងនិងពេលវេលាដែលត្រូវ

ផ្តល់ឱ្យឬត្រូវតំឡើងបរិក្ខារ ពីលក្ខខណ្ឌនៃការធានានិងថែទាំ និងពីបណ្តាលក្ខខណ្ឌពាក់ព័ន្ធដទៃទៀត ។ នៅក្នុងសេចក្តីបញ្ជាក់លក្ខណៈបច្ចេកទេស ត្រូវអធិប្បាយរាល់ចំនុចសំខាន់ៗនៃមុខទំនិញដែលត្រូវជាវ និងត្រូវបញ្ជាក់ថា ក្នុងករណីដែលពុំមានការអនុលោមតាមចំនុចសំខាន់ៗខាងលើ ការដេញថ្លៃនឹងត្រូវចាត់ទុកថាពុំអាចយកជាការបាន ។ រាល់រូបគំនូរត្រូវតែស៊ីសង្វាក់គ្នាជាមួយអត្ថបទនៃសេចក្តីបញ្ជាក់លក្ខណៈបច្ចេកទេស ។ ប្រសិនបើមានការអនុញ្ញាតឱ្យទទួលសំណើដេញថ្លៃផ្សេងៗបាន នោះគេត្រូវថែងចំនុចនេះឱ្យបានច្បាស់ ។ ឯកសារដេញថ្លៃត្រូវបញ្ជាក់ពីវិធី លក្ខខណ្ឌនៃការវាយតំលៃការដេញថ្លៃ និងបណ្តាកត្តាដែលត្រូវពិចារណាក្នុងការប្រៀបធៀបសំណើដេញថ្លៃនានា ។

2.16 រាល់ពត៌មានបន្ថែម ការបំភ្លឺ ការកែកំហុស ឬការកែប្រែនៅក្នុងឯកសារដេញថ្លៃ ត្រូវតែផ្ញើជូនទៅគ្រប់ភាគីទាំងអស់ ដែលបានទទួលឯកសារសំណៅដើម ។ ក្នុងករណីដែលមានការកែប្រែច្រើនលើឯកសារដេញថ្លៃ ត្រូវទុកពេលគ្រប់គ្រាន់ សំរាប់ឱ្យអ្នកចូលរួមដេញថ្លៃអាចធ្វើការកែតំរូវលើសំណើដេញថ្លៃរបស់ខ្លួន ដើម្បីឆ្លើយតបនឹងការកែប្រែនេះ ។ រយៈពេល 30ថ្ងៃ អាចចាត់ទុកថាគ្រប់គ្រាន់ សំរាប់គោលបំនងនេះ ក្នុងករណីដែលមានការកែប្រែច្រើន ។

## ប្រាក់កក់ដេញថ្លៃ

2.17 ប្រាក់កក់ដេញថ្លៃអាចត្រូវការជាចាំបាច់ ដើម្បីរក្សាសុពលភាពនៃការដេញថ្លៃសំរាប់រយៈពេល ដែលបានកំនត់នៅក្នុងលិខិតអញ្ជើញចូលរួមដេញថ្លៃ ។ ប៉ុន្តែ គេក៏មិនត្រូវកំនត់វាឱ្យខ្ពស់ពេកទេ ព្រោះវាធ្វើឱ្យខូចទឹកចិត្តអ្នកចូលដេញថ្លៃ ។ ចំនួននេះត្រូវឆ្លុះបញ្ចាំងពីការវាយតំលៃសមហេតុផលរបស់ភាគីខ្ចីឥណទាន អំពីបរិមាណនៃការខាតបង់ដែលអាចនឹងកើតឡើង ប្រសិនបើអ្នកចូលដេញថ្លៃដកពាក្យ ឬបដិសេធមិនព្រមចុះហត្ថលេខាលើកិច្ចសន្យា ។ ជាទូទៅ បរិមាណកំនត់សំរាប់ប្រាក់កក់ដេញថ្លៃត្រឹមពីរភាគរយនៃថ្លៃកំនត់ដាក់ឱ្យដេញ ចាត់ទុកថាសមរម្យ និងយុត្តិធម៌ ។ អាស្រ័យតាមការជ្រើសរើសរបស់អ្នកចូលដេញថ្លៃ ប្រាក់កក់ដេញថ្លៃអាចជា មូលប្បទានប័ត្រដែលមានការបញ្ជាក់ថាត្រឹមត្រូវ លិខិតឥនទាន ឬលិខិតធានាពីធនាគារដែលមានឈ្មោះល្អ ។ ប្រាក់កក់ដេញថ្លៃត្រូវបង្វិលជូនទៅអ្នកដែលមិនបានទទួលជោគជ័យក្នុងការដេញថ្លៃភ្លាម ក្រោយពេលជ្រើសរើសអ្នកទទួលជោគជ័យក្នុងការដេញថ្លៃរួចហើយ ។

## លក្ខខណ្ឌនៃកិច្ចសន្យា

2.18 កិច្ចសន្យាត្រូវមានបញ្ជាក់លក្ខខណ្ឌទូទៅ ដែលអាចរួមមាន ការកំនត់ទំហំនៃការងារដែលត្រូវអនុវត្ត ឬប្រភេទទំនិញដែលត្រូវផ្គត់ផ្គង់, សិទ្ធិនិងកាតព្វកិច្ចរបស់ភាគីខ្ចីឥណទាន និងភាគីម៉ៅការឬអ្នកផ្គត់ផ្គង់, ព្រមទាំង

អំពីអំណាច និងសមត្ថកិច្ចនៃវិស្វករឬស្ថាបត្យករដែលអាចជួលដោយភាគីខ្ចីឥណទានក្នុងការអនុវត្តន៍កិច្ចសន្យា, លក្ខខណ្ឌទូទាត់ការចំណាយ (រួមទាំងការបង់ប្រាក់មុន ប្រសិនបើមាន), ខចែងពីប្រាក់កក់, ប្រាក់រក្សាទុក, ខចែងពីការកែតំរូវថ្លៃ, ការធានារ៉ាប់រង, និងសំណងព្រាងទុក ។ បន្ថែមពីលើលក្ខខណ្ឌទូទៅ ត្រូវមានដាក់បញ្ចូលលក្ខខណ្ឌពិសេសសមស្របតាមប្រភេទទំនិញ ឬការងារ ឬគំរោងផងដែរ ។

## បទដ្ឋាន

2.19 ប្រសិនបើមានការបញ្ជាក់ពីបទដ្ឋានច្បាស់លាស់សំរាប់បរិក្ខារ ឬសំភារៈ នោះក្នុងសេចក្តីបញ្ជាក់លក្ខណៈបច្ចេកទេសត្រូវចែងថា រាល់ទំនិញត្រូវស្របតាមបទដ្ឋានផ្លូវការនានា ដែលធានាគុណភាពដូចគ្នា ឬខ្ពស់ជាងបទដ្ឋានដែលបានចែង ។

## ការប្រើប្រាស់ឈ្មោះពាណិជ្ជកម្ម

2.20 សេចក្តីបញ្ជាក់លក្ខណៈបច្ចេកទេសត្រូវធ្វើ ដោយផ្អែកលើតំរូវការសំរាប់ការអនុវត្តន៍ ហើយត្រូវចៀសវាងការនិយាយយោងដល់ផ្លាកឈ្មោះពាណិជ្ជកម្ម លេខបញ្ជី ឬឯកសារពាក់ព័ន្ធ លើកលែងតែមានការចាំបាច់ ដើម្បីធានាថា មានការដាក់បញ្ចូលនូវលក្ខណៈសំខាន់ៗខ្លះ ។ ក្នុងករណីបែបនេះត្រូវសរសេរជាអក្សរនៅពីក្រោយសេចក្តីយោងថា "ឬសមមូល" ហើយសេចក្តីបញ្ជាក់លក្ខណៈបច្ចេកទេសត្រូវអនុញ្ញាត ឱ្យមានការផ្តល់មុខទំនិញជំរើសផ្សេងទៀត ដែលមានគុណភាព និងអាចប្រើប្រាស់បានយ៉ាងហោចណាស់ដូចគ្នានឹងប្រភេទទំនិញដែលមានចែងក្នុងកិច្ចសន្យា ។

## ប្រភពនៃលទ្ធកម្ម

2.21 ក្នុងករណីនៃកម្ចីឥណទានពីធនធានទុនទូទៅ ឯកសារដេញថ្លៃត្រូវបញ្ជាក់ថា ការទូទាត់លើចំណាយដោយប្រើទឹកប្រាក់កម្ចីឥណទានពីធនាគារអភិវឌ្ឍន៍អាស៊ី នឹងធ្វើទៅសំរាប់តែមុខទំនិញ ដែលផលិតក្នុងបណ្តាប្រទេសជាសមាជិកនៃធនាគារអភិវឌ្ឍន៍អាស៊ី និងសេវាកម្មដែលផ្តល់ដោយបណ្តាប្រទេសទាំងនោះប៉ុណ្ណោះ ។ ក្នុងករណីនៃកម្ចីឥណទានពីធនធានមូលនិធិពិសេស ការទូទាត់នេះត្រូវធ្វើឡើងសំរាប់តែមុខទំនិញ និងសេវាកម្ម ដែលផលិត ឬផ្តល់ដោយបណ្តាប្រទេសជឿនលឿនជាសមាជិក ដែលបានរួមវិភាគទានដល់ធនធានមូលនិធិនេះ និងសំរាប់មុខទំនិញ និងសេវាកម្ម ដែលផលិត ឬផ្តល់ដោយបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ជាសមាជិកទាំងអស់ផងដែរ ។

## ការកំនត់ថ្លៃ

2.22 (ក) ការដេញថ្លៃសំរាប់ផ្គត់ផ្គង់ទំនិញនឹងត្រូវអញ្ជើញ ដោយផ្អែកលើ CIF[3] ឬ CIP[3] ចំពោះរាល់ទំនិញនាំចូលពីបរទេស និង EXW[4] ចំពោះគ្រប់មុខទំនិញដែលមាន ឬផលិត ឬតំឡើងនៅក្នុងស្រុក រួមទាំងបណ្តាទំនិញដែលបាននាំចូលរួចហើយតាំងពីមុនមក ។ ក្នុងករណីដែលអ្នកចូលដេញថ្លៃត្រូវការឱ្យមានជាចាំបាច់ នូវការដឹកជញ្ជូនផ្លូវគោក ការតំឡើង ការប្រគល់សិទ្ធិបន្ត ឬសេវាកម្មស្រដៀងគ្នានេះដទៃទៀត សំរាប់អនុវត្តគំរោង ដូចជាក្នុងករណីនៃកិច្ចសន្យា "ផ្គត់ផ្គង់និងតំឡើង" អ្នកចូលដេញថ្លៃត្រូវដាក់ជាមួយនូវបញ្ជីកំនត់តំលៃសំរាប់សេវាកម្មទាំងនេះដោយឡែក ។

(ខ) ប្រសិនបើភាគីខ្ចីឥណទាន មានបំណងបំរុងទុកការដឹកជញ្ជូននិងការធានារ៉ាប់រងសំរាប់ការនាំចូលទំនិញ ឱ្យទៅកុមហ៊ុនក្នុងស្រុក ឬតាមរយៈប្រភពផ្សេងទៀត នោះអ្នកចូលដេញថ្លៃត្រូវកំនត់ថ្លៃ FOB[3] ឬ CFR[3] បន្ថែម ពីលើ CIF ឬ CIP ដែលមានបញ្ជាក់ក្នុងវាក្យខ័ណ្ឌ (ក) ខាងលើ ។ ការជ្រើសរើសយកថ្លៃទាបជាងគេក្នុងការដេញថ្លៃ ត្រូវផ្អែកលើមូលដ្ឋាននៃថ្លៃ CIF ឬ CIP ប៉ុន្តែភាគីខ្ចីឥណទានអាចចុះហត្ថលេខាលើកិច្ចសន្យាស្តីពីលក្ខខណ្ឌ FOB ឬ CFR និងចាត់ចែងការដឹកជញ្ជូន និង/ឬថ្លៃធានារ៉ាប់រង ដោយខ្លួនឯង ។

2.23 ក្នុងករណីនៃកិច្ចសន្យាសោក្នុងដៃ អ្នកចូលដេញថ្លៃត្រូវកំនត់ថ្លៃតំលើងរោងចក្រនៅនឹងកន្លែង រួមទាំងចំណាយសំរាប់ការផ្គត់ផ្គង់បរិក្ខារ ថ្លៃដឹកជញ្ជូនតាមសមុទ្រ ថ្លៃដឹកជញ្ជូនក្នុងស្រុក ថ្លៃធានារ៉ាប់រង ថ្លៃតំលើងនិង

---

[3] យោងតាមពាក្យកាត់ INCOTERMS, CIF (cost, insurance and freight) មានន័យថា ជាថ្លៃទំនិញ ថ្លៃធានារ៉ាប់រង និងថ្លៃដឹកជញ្ជូន សំរាប់ការដឹកនាំតាមផ្លូវសមុទ្រ ។ CIP (carriage and insurance paid) មានន័យថា ថ្លៃដឹកជញ្ជូន និងថ្លៃធានារ៉ាប់រង ដែលបង់ដោយអ្នកលក់ (ឈ្មោះគោលដៅនៃការដឹកជញ្ជូន) ក្នុងករណីនៃការដឹកជញ្ជូនតាមមធ្យោបាយច្រើនបែប ។ FOB (free on board) មានន័យថា រាល់ការចំណាយដឹកជញ្ជូន និងផ្ទុកលើនាវាត្រូវចេញរួចរាល់ដោយអ្នកប្រគល់ទំនិញ ។ CFR (cost and freight) មានន័យថា ថ្លៃទំនិញនិងថ្លៃដឹកជញ្ជូន ។

[4] EXW (ex works) មានន័យថា ប្រគល់នៅរោងចក្រ, ex factory (ថ្លៃនៅរោងចក្រ) ឬ off-the-shelf ។ ថ្លៃ EXW ត្រូវរួមបញ្ចូលពន្ធគ្រប់ប្រភេទ ដូចជាពន្ធលក់ និងពន្ធដទៃទៀត ដែលបានបង់រួចហើយ ឬដែលត្រូវបង់ សំរាប់ផ្នែកណាមួយ និងសំរាប់វត្ថុធាតុដើមដែលប្រើប្រាស់ក្នុងការផលិត ឬតំឡើងបរិក្ខារនោះ ឬបណ្តាបរិក្ខារដែលបាននាំចូលរួចមកហើយពីពេលមុនមក ដែលត្រូវផ្គត់ផ្គង់នៅក្នុងក្របខ័ណ្ឌនៃការដេញថ្លៃ ។

ការប្រគល់សិទ្ធិ ក៏ដូចជាថ្លៃការងារពាក់ព័ន្ធ និងថ្លៃសេវាកម្មទាំងអស់ដែលរួមបញ្ចូលក្នុងកិច្ចសន្យា ដូចជាការគូរប្លង់ ការថែទាំ និងប្រតិបត្តិការជាដើម ។ លើកលែងតែមានចែងដោយឡែកក្នុងឯកសារដេញថ្លៃ ថ្លៃពាក់ព័ន្ធនឹងកិច្ចសន្យាសោក្នុងដៃ ត្រូវរួមបញ្ចូលរាល់ពន្ធ អាករ និងវិភាគទានដទៃទៀត ។

2.24 អ្នកចូលដេញថ្លៃសំរាប់កិច្ចសន្យាការងារស៊ីវិល ត្រូវកំនត់ថ្លៃក្នុងមួយឯកតា ឬថ្លៃសរុប សំរាប់អនុវត្តការងារទាំងនោះ ហើយថ្លៃទាំងនោះត្រូវមានដាក់បញ្ចូលរាល់ពន្ធ អាករ និងវិភាគទានដទៃទៀត ។ អ្នកចូលដេញថ្លៃត្រូវអនុញ្ញាតឱ្យទទួលពតិមានពីគ្រប់ប្រភពស្របច្បាប់ទាំងអស់ ដើម្បីឱ្យពួកគេអាចកំនត់តំលៃដាក់ដេញ ដោយការប្រកួតប្រជែងបំផុត ។

## ខស្តីពីរូបិយវត្ថុ

### 2.25 រូបិយវត្ថុប្រើក្នុងការដេញថ្លៃ

(ក) នៅក្នុងឯកសារដេញថ្លៃ ត្រូវមានបញ្ជាក់អំពីរូបិយវត្ថុមួយ ឬច្រើនប្រភេទ ដែលត្រូវប្រើក្នុងការដេញថ្លៃ ។ ជាធម្មតាឯកសារដេញថ្លៃតំរូវឱ្យអ្នកចូលដេញថ្លៃកំនត់ថ្លៃ តាមរូបីយវត្ថុក្នុងស្រុករបស់អ្នកដេញថ្លៃ ឬតាមរូបិយវត្ថុពាណិជ្ជកម្មអន្តរជាតិ ដែលមានចែងក្នុងឯកសារដេញថ្លៃ ។

(ខ) ក្នុងករណីដែលអ្នកដេញថ្លៃរំពឹងថា មានការចំណាយខ្លះជារូបីយវត្ថុផ្សេងពីរូបីយវត្ថុប្រទេសខ្លួន ក្នុងការផលិតទំនិញសំរាប់ផ្គត់ផ្គង់ នោះតំលៃដាក់ដេញថ្លៃក៏អាចកំនត់ជារូបីយវត្ថុប្រភេទផ្សេង ក្នុងចំនួនតាមការប្រមាណលើចំណាយតាមរូបិយវត្ថុប្រភេទនោះ ។

(គ) ប្រសិនបើការចំណាយខ្លះនៅក្នុងកិច្ចសន្យា អាចត្រូវធ្វើទៅនៅក្នុងប្រទេសជាភាគីខ្ចីឥណទាន នោះចំណែកនៃតំលៃដាក់ដេញសំរាប់ចំណាយប្រភេទនេះ អាចត្រូវកំនត់តាមការប៉ាន់ស្មានជារូបីយវត្ថុនៃប្រទេសនោះ ។

(ឃ) ក្នុងករណីនៃការងារស៊ីវិល ឯកសារដេញថ្លៃអាចតំរូវឱ្យអ្នកចូលដេញថ្លៃបញ្ជាក់តំលៃដាក់ដេញ ជារូបិយវត្ថុនៃប្រទេសអ្នកខ្ចីឥណទានទាំងស្រុង ។ ក្នុងករណីនេះ អ្នកចូលដេញថ្លៃនឹងត្រូវអនុញ្ញាត ឱ្យបញ្ជាក់ពីអត្រាប្តូរប្រាក់បរទេស ជាភាគរយនៃតំលៃដែលខ្លួនដាក់ដេញ ។

### 2.26 រូបិយវត្ថុសំរាប់ប្រៀបធៀបសំណើដេញថ្លៃ

(ក) ដើម្បីប្រៀបធៀបសំណើដេញថ្លៃ រាល់តំលៃដាក់ដេញត្រូវវាយតំលៃដោយប្រើប្រាស់រូបិយវត្ថុតែមួយបែប ដែលកំនត់ដោយភាគីខ្ចីឥណទាន និងដែលមានបញ្ជាក់ក្នុងឯកសារដេញ

ថ្លៃ ។ អត្រាប្តូររូបិយវត្ថុប្រើក្នុងការវាយតំលៃបែបនេះ ត្រូវតែជាអត្រាលក់ជាផ្លូវការ ដែលមានកំនត់សំរាប់កិច្ចការជំនួញស្រដៀងគ្នា និងទៅតាមកាលបរិច្ឆេទកំនត់ក្នុងឯកសារដេញថ្លៃ ដោយអនុលោមតាមបណ្តាខចែងក្នុងកថាខ័ណ្ឌរង (ខ) ខាងក្រោម ។ ក្នុងករណីពុំមានអត្រាប្តូររូបិយវត្ថុជាផ្លូវការ ភាគីខ្ចីឥណទានត្រូវពិគ្រោះជាមួយធនាគារអភិវឌ្ឍន៏អាស៊ី ដើម្បីកំនត់អត្រាប្តូររូបិយវត្ថុសំរាប់ប្រើប្រាស់ ។

(ខ) កាលបរិច្ឆេទ ដែលកំនត់ក្នុងឯកសារដេញថ្លៃសំរាប់ប្រៀបធៀបតំលៃដាក់ដេញ ដូចមានចែងក្នុងកថាខ័ណ្ឌរង (ក) ខាងលើ មិនត្រូវមានរយៈពេលឆាប់ជាង ៣០ ថ្ងៃ មុនកាលកំនត់សំរាប់ការដាក់ជូនតំលៃដេញឡើយ ហើយក៏មិនត្រូវយូរជាងកាលបរិច្ឆេទដើម ដែលកំនត់សំរាប់ការផុតកំនត់សុពលភាពនៃតំលៃដាក់ដេញនោះឡើយ ។

### 2.27 រូបិយវត្ថុសំរាប់ទូទាត់ និងការប្រថុយប្រថាននៃការប្តូរប្រាក់

(ក) ការទូទាត់ចំណាយតាមកិច្ចសន្យា ត្រូវធ្វើតាមរយៈរូបិយវត្ថុមួយ ឬច្រើនប្រភេទ ដូចដែលតំលៃចែងក្នុងសំណើដេញថ្លៃដែលឈ្នះគេ លើកលែងតែមានការចាត់ចែងផ្សេងណាមួយអាចបញ្ជាក់ហេតុផលច្បាស់លាស់ និងដែលមានចែងក្នុងឯកសារដេញថ្លៃ ។

(ខ) ក្នុងករណីការទូទាត់ចំណាយត្រូវធ្វើទាំងស្រុង ឬជាចំណែកតាមរូបិយវត្ថុមួយបែប ឬច្រើនបែបផ្សេងពីប្រភេទរូបិយវត្ថុដែលមានកំនត់ក្នុងសំណើដេញថ្លៃ ភាគីក្នុងកិច្ចសន្យា ឬក្រុមហ៊ុនផ្គត់ផ្គង់ នឹងមិនទទួលខុសត្រូវចំពោះការខាតបង់ដោយសារការប្រថុយប្រថាននៃការប្តូរប្រាក់ឡើយ ។ ហេតុនេះ កិច្ចសន្យាត្រូវបញ្ជាក់ថា ចំនួនទឹកប្រាក់ត្រូវបង់ជារូបិយវត្ថុមួយ ឬច្រើនបែប ដែលខុសពីរូបិយវត្ថុចែងក្នុងសំណើដេញថ្លៃ ត្រូវគណនាតាមអត្រាប្តូររូបិយវត្ថុ រវាងរូបិយវត្ថុទាំងនោះ ដែលបានកំនត់ក្នុងឯកសារដេញថ្លៃ ។ ករណីដូចគ្នានេះដែរនឹងត្រូវអនុវត្ត សំរាប់កិច្ចសន្យាការងារស៊ីវិល ក្នុងករណីដែលថ្លៃដេញត្រូវបានកំនត់ជារូបិយវត្ថុនៃប្រទេសជាភាគីខ្ចីឥណទាន [សូមអានកថាខ័ណ្ឌ 2.25 (ឃ)] ឯតំលៃមួយភាគនៃការចំណាយជារូបិយវត្ថុផ្សេង នឹងត្រូវទូទាត់ទៅតាមរូបិយវត្ថុប្រភេទនោះ ។

## លក្ខខណ្ឌ និងរបៀបទូទាត់

2.28 ជាទូទៅ ការទូទាត់ត្រូវធ្វើតាមបទដ្ឋានពាណិជ្ជកម្មអន្តរជាតិ ហើយការផ្ទេរប្រាក់ឥណទានត្រូវធ្វើអនុលោមតាមនីតិវិធី ដែលមានចែងក្នុង "សៀវភៅណែនាំស្តីពីការផ្ទេរប្រាក់ឥណទាន" របស់ធនាគារអភិវឌ្ឍន៍អាស៊ី (ដែលមានការធ្វើវិសោធនកម្មជារឿយៗ) ។

## ខស្តីពីការកែតំរូវថ្លៃ

2.29 ឯកសារដេញថ្លៃត្រូវបញ្ជាក់ច្បាស់ថា តើអាច ឬមិនអាចឱ្យមានការអនុញ្ញាតកែតំរូវថ្លៃ ក្នុងករណីដែលមានការប្រែប្រួលថ្លៃសំរាប់ចំណែកចំបងណាមួយនៃការងារក្នុងកិច្ចសន្យា ដូចជាថ្លៃពលកម្ម បរិក្ខារ និងសំភារៈ ដែលភាគីក្នុងកិច្ចសន្យាមិនអាចត្រួតត្រាបាន ។ ការកែតំរូវថ្លៃពុំចាំបាច់មានចែងទេក្នុងករណីនៃកិច្ចសន្យាផ្គត់ផ្គង់ងាយៗ ពាក់ព័ន្ធនឹងការប្រគល់ទំនិញរយៈពេលខ្លី ។ ប៉ុន្តែ សំរាប់កិច្ចសន្យាប្រគល់ទំនិញរយៈពេលវែង ឬសំរាប់គំរោងដែលមានរយៈពេលវែង (ជាទូទៅលើសពី 12 ខែ) រួមទាំងកិច្ចសន្យាការងារស៊ីវិលសំខាន់ៗ គេត្រូវមានចែងពីការកែតំរូវថ្លៃ ។ កិច្ចសន្យាដែលពាក់ព័ន្ធនឹងមុខទំនិញធំៗ ដែលថ្លៃរបស់វាអាចប្រែប្រួលយ៉ាងខ្លាំងក្នុងរយៈពេលខ្លី ត្រូវមានចែងពីការឡើង ឬចុះថ្លៃ ដែលជួយការពារទាំងភាគីខ្ចីឥណទាន ទាំងភាគីម៉ៅការ ពីការខាតបង់ ក្នុងករណីដែលមានការប្រែប្រួលថ្លៃឆាប់រហ័ស ។

2.30 បរិមាណនៃការកែតំរូវថ្លៃ ត្រូវផ្អែកលើភាពប្រែប្រួលនៃថ្លៃរបស់សមាសភាគចំបងៗក្នុងកិច្ចសន្យា ។ វិធីធ្វើការកែតំរូវ ដែលត្រូវមានចែងក្នុងឯកសារដេញថ្លៃ អាចអនុញ្ញាតឱ្យធ្វើការតែតំរូវ ដោយផ្អែកលើភ័ស្តុតាងនៃឯកសារនានា ដែលផ្តល់ដោយភាគីម៉ៅការ ឬដោយគណនាតាមរូបមន្តមួយ ឬច្រើន សំរាប់ការកែតំរូវថ្លៃ ។ ការប្រៀបធៀបតំលៃដាក់ដេញត្រូវផ្អែកតែលើថ្លៃមូលដ្ឋានតែប៉ុណ្ណោះ ។

## ការទូទាត់ជាមុន

2.31 ក្នុងកិច្ចសន្យាសាងសង់ គេអាចអនុញ្ញាតឱ្យមានការទូទាត់ប្រាក់ជាមុន សំរាប់ចំណាយលើការងារចាប់ផ្តើម និងថ្លៃសំភារៈបញ្ជូនដល់កន្លែងសាងសង់សំរាប់ដំណើរការ ។ ឯកសារដេញថ្លៃត្រូវបញ្ជាក់មូលដ្ឋានសំរាប់ការកំនត់ចំនួនទឹកប្រាក់ដែលអាចទូទាត់ជាមុនសំរាប់ករណីនីមួយៗ, ពេលវេលា និងវិធីទូទាត់, ប្រភេទប្រាក់កក់ដែលចាំបាច់ និងរបៀបដែលភាគីម៉ៅការត្រូវទូទាត់សងវិញ ។ ពាក់ព័ន្ធនឹងការផ្តល់ប្រាក់ជាមុនសំរាប់ចាប់ផ្តើមដំណើរការងារ បណ្តាមុខការដែលត្រូវការចំនាយជាមុន ត្រូវមានរាយបញ្ជាក់ក្នុងប័ណ្ណបញ្ជាក់នូវបរិមាណ ហើយចំនួនទឹកប្រាក់ដែលត្រូវផ្តល់ជាមុន ត្រូវកំហិតត្រឹមសំរាប់ការចំណាយតាមប្រភេទមុខការងារដែលបានរៀបរាប់នោះតែប៉ុណ្ណោះ ។

## ប្រាក់កក់សំរាប់ការអនុវត្តន៍ និងប្រាក់រក្សាទុក

2.32 ក្នុងឯកសារដេញថ្លៃ ត្រូវបញ្ជាក់ពីតំរូវការឱ្យដាក់ប្រាក់កក់តាមរូបភាពណាមួយ ដើម្បីជួយធានាថា ការងារនឹងត្រូវអនុវត្តឱ្យបានរហូតដល់ទីបញ្ចប់ ក្នុងករណីដែលអ្នកម៉ៅការពុំអាចបំពេញទៅតាមកិច្ចសន្យា ។ ក្នុងកិច្ចសន្យាការងារស៊ីវិល អ្នកម៉ៅការត្រូវមានប្រាក់កក់សំរាប់ការអនុវត្តន៏ ជាការធានាដោយធនាគារ ឬមានប្រាក់តំកល់ទុក ហើយដែលការធានានោះត្រូវមានសុពលភាពរហូតដល់ចុងបញ្ចប់នៃកិច្ចសន្យា ។ ចំនួនទឹកប្រាក់កក់អាចប្រែប្រួលទៅតាមប្រភេទ និងទំហំនៃការងារដែលត្រូវអនុវត្ត ។ ជាទូទៅ ចំនួននេះមាន 10% នៃតំលៃក្នុងកិច្ចសន្យា ដែលជាបរិមាណសមរម្យ សំរាប់ការពារភាគីខ្ចីឥណទានបាន ។ លើសពីនេះ គេអាចតំរូវឱ្យរក្សាទុកប្រាក់មួយចំនួន មិនលើសពី 10% នៃចំនួនទឹកប្រាក់ដែលត្រូវទូទាត់ ដើម្បីធានាថា អ្នកម៉ៅការនឹងគោរពតាមកាតព្វកិច្ចធានា និងការទទួលថែរក្សារបស់ខ្លួន ។ ចំនួនទឹកប្រាក់នេះនឹងត្រូវរក្សាទុក រហូតដល់ផុតពេលកំនត់សុពលភាពនៃការសន្យាធានាគុណភាព ឬធានាថែរក្សា ។ ក្រោយពេលបញ្ចប់ការងារ ប៉ុន្តែមុនពេលផុតកំនត់សុពលភាពនៃការសន្យាធានាគុណភាព ឬការថែរក្សា អ្នកខ្ចីឥណទានអាចមានជំរើសក្នុងការប្តូរចំនួនទឹកប្រាក់រក្សាទុកនោះ ជាមួយនឹងការធានាដោយធនាគារ ឬរូបភាពណាមួយផ្សេងទៀតនៃប្រាក់កក់ដែលសមស្រប ។

2.33 ចំពោះកិច្ចសន្យាផ្គត់ផ្គង់ទំនិញ គេអាចតំរូវឱ្យមានប្រាក់កក់សំរាប់ការអនុវត្តន៏ ក្រោមរូបភាពជាប័ណ្ណធានាដោយធនាគារ ឬការរក្សាទុកប្រាក់មួយចំនួន ដើម្បីធានាថា បរិក្ខារផ្គត់ផ្គង់នោះ មានគុណភាពដូចមានចែងក្នុងសេចក្តីបញ្ជាក់បច្ចេកទេសនៅក្នុងរយៈពេលនៃការធានា ។ ទោះបីចំនួនទឹកប្រាក់កក់ប្រែប្រួលទៅតាមលក្ខខណ្ឌទីផ្សារ និងទំលាប់អនុវត្តក្នុងមុខជំនួញទាក់ទងនឹងប្រភេទមុខទំនិញណាមួយក្តី ជាទូទៅចំនួននេះអាចមានពី 5% ទៅ 10% នៃចំនួនទឹកប្រាក់ក្នុងកិច្ចសន្យា ។

## ការធានារ៉ាប់រង និងការដឹកជញ្ជូន

2.34 ឯកសារដេញថ្លៃត្រូវបញ្ជាក់ឱ្យច្បាស់លាស់ ពីប្រភេទនៃការធានារ៉ាប់រង ដែលត្រូវផ្តល់ដោយអ្នកដេញថ្លៃឈ្នះ និងត្រូវបញ្ជាក់ពីប្រភេទនៃការប្រថុយប្រថានដែលត្រូវមានការធានារ៉ាប់រង ទឹកប្រាក់ដែលត្រូវទូទាត់សង និងរយៈពេលសុពលភាពនៃការធានារ៉ាប់រង ។ ក្នុងកិច្ចសន្យាផ្គត់ផ្គង់ទំនិញផ្អែកតាម CIF និង CIP ការធានារ៉ាប់រងទំនិញ និងការដឹកជញ្ជូនត្រូវទទួលចាត់ចែងដោយអ្នកផ្គត់ផ្គង់ និងត្រូវចាត់ទុកជាផ្នែកមួយនៃកិច្ចសន្យា ។ ក្នុងករណីដែលទំនិញត្រូវផ្គត់ផ្គង់តាមប្រព័ន្ធ FOB ឬ CFR ហើយការធានារ៉ាប់រងលើទំនិញ និង/ឬការដឹកជញ្ជូន ត្រូវចាត់ចែងដោយឡែកដោយភាគីខ្ចីឥណទាន ប្រសិនបើធនាគារអភិវឌ្ឍន៏អាស៊ី ត្រូវបានស្នើសុំឱ្យផ្តល់ហិរញ្ញវត្ថុសំរាប់បំពេញ

ការចំណាយបែបនេះ នោះធនាគារអភិវឌ្ឍន៍អាស៊ីត្រូវទទួលការធានាថា ពុំមានការដាក់លក្ខខណ្ឌច្រើនហួសហេតុលើការជាវការធានារ៉ាប់រងបែបនោះ និង/ឬ ការដឹកជញ្ជូនឡើយ ហើយត្រូវមានការយកចិត្តទុកដាក់សមស្របលើប្រសិទ្ធិភាពសេដ្ឋកិច្ច និងសមិទ្ធផល ។ ប្រសិនបើភាគីខ្ចីឥណទានមិនចង់ទិញការធានារ៉ាប់រងពីទីផ្សារទេនោះ គេត្រូវមានភ័ស្តុតាងផ្តល់ដល់ធនាគារអភិវឌ្ឍន៍អាស៊ី ថាគេមានធនធានសំរាប់ទូទាត់ជាបន្ទាន់ចំពោះការខូចខាត ឬការបាត់បង់ទំនិញ តាមរយៈរូបិយវត្ថុដែលអាចដូរបានដោយសេរី ។

## សំណងព្រាងទុក

2.35 សំណងព្រាងទុក ឬការទូទាត់ប្រហែលគ្នានេះ ដែលជាធម្មតាមិនលើសពី 10% នៃតំលៃសរុបក្នុងកិច្ចសន្យា ត្រូវមានចែងក្នុងឯកសារដេញថ្លៃ ដើម្បីទូទាត់ដល់ភាគីខ្ចីឥណទាន ក្នុងករណីដែលការពន្យារពេលបញ្ចប់ការងារ ឬផ្តល់ទំនិញ នាំឱ្យភាគីខ្ចីឥណទានត្រូវមានចំណាយជាបន្ថែម បាត់បង់ចំណូល ឬ បាត់បង់ប្រយោជន៍ផ្សេងទៀត ។ កិច្ចសន្យាក៏អាចចែងពីការផ្តល់ជារង្វាន់ទៅអ្នកម៉ៅការ ក្នុងករណីដែលការងារក្នុងកិច្ចសន្យាត្រូវបានបញ្ចប់មុនពេលកំនត់ ហើយមកនូវផលប្រយោជន៍ដល់អ្នកខ្ចីឥណទាន ។ នៅក្នុងកិច្ចសន្យាដែលផ្តល់ហិរញ្ញវត្ថុដោយធនាគារអភិវឌ្ឍន៍អាស៊ី ការតំរូវឱ្យអ្នកម៉ៅការ ឬភាគីខ្ចីឥណទាន ទូទាត់សងឱ្យភាគីផ្សេងទៀត ចំពោះការខូចខាតដោយផ្ទាល់ ឬ ដែលកើតមានជាក្រោយ ជាប្រការមិនអាចទទួលយកបានឡើយ ។

## ប្រធានសក្តិ

2.36 លក្ខខណ្ឌនៃកិច្ចសន្យាក្នុងឯកសារដេញថ្លៃត្រូវចែងច្បាស់ថា ការខកខាននៃភាគីណាមួយក្នុងការបំពេញកាតព្វកិច្ចណាមួយរបស់ខ្លួន ដែលមានចែងក្នុងកិច្ចសន្យាមិនត្រូវចាត់ទុកថាជាកំហុសបានទេ ប្រសិនបើការខកខាននោះកើតឡើងបណ្តាលមកពីប្រធានសក្តិ ដូចដែលមានកំនត់ក្នុងកិច្ចសន្យា ។

## ការដោះស្រាយទំនាស់

2.37 ក្នុងករណីអាចធ្វើបាន លក្ខខណ្ឌក្នុងកិច្ចសន្យាត្រូវមានចែងពីបណ្តាខពាក់ព័ន្ធនឹងច្បាប់ជាធរមាន និងវេទិកាសំរាប់ដោះស្រាយទំនាស់ ។ ការកំណត់យកមជ្ឈត្តកម្មពាណិកម្មអន្តរជាតិក្នុងកិច្ចសន្យាផ្គត់ផ្គង់ទំនិញ និងសេវាការងារ អាចចាត់ទុកជាប្រការមានប្រយោជន៍ ។ ប៉ុន្តែ ធនាគារអភិវឌ្ឍន៍អាស៊ីនឹងមិនទទួលសេចក្តីស្នើឱ្យចូលរួមក្នុងការធ្វើមជ្ឈត្តកម្ម មិនទទួលតែងតាំងមជ្ឈត្តករ ឬទទួលធ្វើជាមជ្ឈត្តករឡើយ ។

## គ. ការបើកសំណើដេញថ្លៃ ការវាយតំលៃសំណើដេញថ្លៃ និងការផ្តល់កិច្ចសន្យា

### ចន្លោះពេលរវាងការអញ្ជើញ និងការដាក់សំណើដេញថ្លៃ

2.38 ចន្លោះពេលដែលអនុញ្ញាតសំរាប់ការរៀបចំ និងការដាក់សំណើដេញថ្លៃ នឹងអាស្រ័យជាសំខាន់លើវិសាលភាព និងភាពសាំញ៉ាំនៃកិច្ចសន្យា ។ ស្ថានភាពជាក់លាក់នានានៃគំរោងក៏ត្រូវដាក់ចូលសំរាប់ការពិចារណាផងដែរ ។ ជាទូទៅ គេអាចផ្តល់រយៈពេលយ៉ាងតិច 60 ថ្ងៃ សំរាប់កិច្ចសន្យាផ្គត់ផ្គង់ និង 90 ថ្ងៃ សំរាប់ការងារស៊ីវិល និងកិច្ចសន្យាសោក្នុងដៃ ដោយរួមទាំងកិច្ចសន្យាគូរប្លង់-សាងសង់ ។ ក្នុងករណីដែលអនុញ្ញាតឱ្យមានតែការប្រកួតប្រជែងក្នុងស្រុក (មើលកថាខ័ណ្ឌ 3.04) រយៈពេលអាចខ្លីជាងនេះ ។ កាលបរិច្ឆេទសំរាប់ដាក់សំណើដេញថ្លៃអាចត្រូវពន្យារពេល ក្នុងករណីដែលការពន្យារពេលបែបនេះនាំមកនូវការប្រកួតប្រជែងច្រើនជាងមុន ។ ក្នុងករណីដែលមានការពន្យារពេលដេញថ្លៃ ត្រូវធ្វើសេចក្តីជូនដំនឹងទៅគ្រប់ភាគីដែលបានទទួល ឬដែលត្រូវបានប្រគល់លិខិតអញ្ជើញឱ្យចូលរួមដេញថ្លៃ ។

### នីតិវិធីបើកសំណើដេញថ្លៃ

2.39 នៅក្នុងលិខិតអញ្ជើញចូលដេញថ្លៃ ត្រូវមានចែងច្បាស់ពី : កាលបរិច្ឆេទ ម៉ោងចុងក្រោយបំផុត ព្រមទាំងទីកន្លែងទទួលសំណើដេញថ្លៃ និងបើកស្រោមសំបុត្រដេញថ្លៃ ។ ពេលវេលាកំណត់សំរាប់បើកស្រោមសំបុត្រដេញថ្លៃ និងកាលកំនត់ចុងក្រោយនៃការទទួលសំណើដេញថ្លៃ ត្រូវតែជាពេលតែមួយ ឬបន្ទាប់គ្នាប្រកិត [5] ។ ភាគីខ្ចីឥណទានត្រូវបើកសំណើដេញថ្លៃទាំងអស់ដែលបានទទួល នៅក្នុងពេល និងទីកន្លែងដែលបានកំនត់ ។ សំណើដេញថ្លៃត្រូវបើកឱ្យឃើញជាសាធារណៈ ពោលគឺបណ្តាអ្នកចូលដេញថ្លៃ និងតំណាងរបស់គេត្រូវទទួលការអនុញ្ញាតឱ្យមានវត្តមាន ។ សំណើថ្លៃដែលទទួលបានក្រោយពេលកំនត់ ត្រូវបញ្ជូនត្រលប់ទៅវិញដោយមិនបើក ។ ឈ្មោះអ្នកចូលដេញថ្លៃ និងចំនួនទឹកប្រាក់សរុបក្នុងសំណើដេញថ្លៃរបស់គេ រួមទាំងជំរើសផ្សេងនៃការដេញថ្លៃ (ប្រសិនបើមាន) ជាមួយនិងសំណើផ្តល់ជូន ការចុះថ្លៃ ត្រូវអានខ្លាំងៗ និងត្រូវកត់ត្រាទុក ហើយកំនត់ត្រានេះមួយច្បាប់ត្រូវផ្ញើជូនជាបន្ទាន់ទៅធនាគារអភិវឌ្ឍន៍អាស៊ី ។

[5] ដើម្បីឱ្យមានពេលគ្រប់គ្រាន់ សំរាប់យកសំបុត្រដេញថ្លៃទៅកាន់កន្លែងប្រកាសជាសាធារណៈ អំពីការបើកស្រោមសំបុត្រដេញថ្លៃ ។

## ការពន្យារពេលសុពលភាពនៃសំណើដេញថ្លៃ

2.40 ត្រូវព្យាយាមបញ្ចប់ការវាយតំលៃសំណើដេញថ្លៃ ឱ្យបានមុនពេលកំនត់ចុងក្រោយនៃសុពលភាពសំណើដេញថ្លៃ ហើយសុពលភាពនៃសំណើដេញថ្លៃនេះមិនត្រូវពន្យារពេលបន្ថែមឡើយ លើកលែងតែក្នុងករណីពិសេស និងដោយមានការឯកភាពជាមុនពីធនាគារអភិវឌ្ឍន៍អាស៊ី ។ នៅពេលដែលពិនិត្យឃើញថា ចាំបាច់ត្រូវមានការពន្យារពេល គ្រប់បណ្ដាអ្នកដែលបានបញ្ជូនសំណើដេញថ្លៃរួចហើយ ត្រូវស្នើឱ្យពន្យារពេលសំណើដេញថ្លៃរបស់ពួកគេ ។ អ្នកដេញថ្លៃ ដែលមានបំណងពន្យារពេលសុពលភាពនៃសំណើដេញថ្លៃរបស់ខ្លួននឹងមិនត្រូវស្នើសុំ ឬអនុញ្ញាតឱ្យធ្វើការកែប្រែណាមួយនៅក្នុងឯកសារដេញថ្លៃរបស់ខ្លួនឡើយ ។ ប្រាក់កក់ដេញថ្លៃរបស់អ្នកដេញថ្លៃ ដែលពុំមានបំណងពន្យារពេលសុពលភាពនៃសំណើដេញថ្លៃរបស់ខ្លួន ត្រូវតែប្រគល់ទៅឱ្យម្ចាស់គេវិញ ។

## ការបំភ្លឺ ឬការកែប្រែសំណើដេញថ្លៃ

2.41 ពុំអនុញ្ញាតឱ្យអ្នកដេញថ្លៃណាមួយ ធ្វើការកែប្រែសំណើដេញថ្លៃរបស់ខ្លួនបានឡើយ ក្រោយពេលដែលសំណើដេញថ្លៃរបស់ខ្លួនត្រូវបានបើកចំហ ប៉ុន្តែបណ្ដាការបំភ្លឺ ដែលមិនផ្លាស់ប្ដូរខ្លឹមសារនៃសំណើដេញថ្លៃរបស់ខ្លួន អាចទទួលយកបាន ។ ភាគីខ្ចីឥណទានអាចសួរអ្នកដេញថ្លៃណាមួយ ឱ្យធ្វើការបំភ្លឺលើសំណើដេញថ្លៃរបស់ខ្លួន ប៉ុន្តែមិនត្រូវសុំឱ្យអ្នកដេញថ្លៃណាមួយ ឱ្យធ្វើការកែប្រែសេចក្ដីនៅក្នុងសំណើដេញថ្លៃរបស់ពួកគេឡើយ ។

## ការសំងាត់នៃនីតិវិធី

2.42 ក្រោយពីការបើកស្រោមសំបុត្រដេញថ្លៃជាសាធារណៈ នឹងពុំមានការផ្សព្វផ្សាយពតិមានអំពីការពិនិត្យ ការបំភ្លឺ និងការវាយតំលៃសំណើដេញថ្លៃ ព្រមទាំងអនុសាសន៍ពាក់ព័ន្ធនឹងសំនើផ្ដល់កិច្ចសន្យា ដល់បុគ្គលណាម្នាក់ដែលពុំមានការពាក់ព័ន្ធជាផ្លូវការជាមួយនីតិវិធីទាំងនេះឡើយ រហូតទាល់តែមានការផ្សព្វផ្សាយអំពីការផ្ដល់កិច្ចសន្យាដល់អ្នកឈ្នះក្នុងការដេញថ្លៃ ។

## ការពិនិត្យសំណើដេញថ្លៃ

2.43 ក្រោយពេលបើកសំណើដេញថ្លៃ គេត្រូវពិនិត្យមើលថា តើមានកំហុសឆ្គងណាមួយក្នុងការគណនានៅក្នុងសំណើដេញថ្លៃ តើសំណើដេញថ្លៃឆ្លើយតបគ្រប់គ្រាន់ទៅនឹងឯកសារដេញថ្លៃដែរទេ តើមានការធានាប្រាក់កក់ដែលចាំបាច់ទេ តើបណ្ដាឯកសារពាក់ព័ន្ធមានចុះហត្ថលេខាត្រឹមត្រូវដែរទេ និងថា តើជាទូទៅសំណើដេញថ្លៃមានភាពទៅត្រឹមត្រូវតាមនីតិវិធីដែរឬទេ ។ ប្រសិនបើសំណើដេញថ្លៃមិនឆ្លើយតបគ្រប់គ្រាន់ទៅនឹងឯកសារដេញថ្លៃទេ ឬ

មានលក្ខខណ្ឌមួយចំនួនដែលមិនអាចទទួលយកបាន សំណើនោះត្រូវទុកជាមោឃៈ ។ បន្ទាប់មក នឹងមានការវិភាគបច្ចេកទេស ដើម្បីវាយតំលៃលើសំណើដេញថ្លៃដែលត្រឹមត្រូវ និងដើម្បីអាចប្រៀបធៀបសំណើដេញថ្លៃនានា ។

## ការវាយតំលៃ និងការប្រៀបធៀបសំណើដេញថ្លៃ

2.44 សំណើដេញថ្លៃនានា ដែលត្រឹមត្រូវតាមសេចក្តីបញ្ជាក់លក្ខណៈបច្ចេកទេស និងដែលឆ្លើយតបគ្រប់គ្រាន់ទៅនឹងឯកសារដេញថ្លៃ នឹងត្រូវយកមកប្រៀបធៀបគ្នា ដោយផ្អែកលើការវាយតំលៃលើថ្លៃដាក់ដេញរបស់វា និងសំណើដេញថ្លៃដែលមានថ្លៃដាក់ដេញទាបជាងគេ តែតាមពិតមិនមែនមានន័យថា សំណើដេញថ្លៃដែលមានថ្លៃដាក់ដេញទាបជាងគេ ត្រូវតែទទួលការជ្រើសរើសសំរាប់ផ្តល់កិច្ចសន្យានោះទេ ។

2.45 (ក) ការវាយតំលៃលើសំណើដេញថ្លៃ ត្រូវតែស្របគ្នាជាមួយវិធីសាស្ត្រ និងលក្ខខណ្ឌនានា ដែលមានចែងក្នុងឯកសារដេញថ្លៃ ។ ក្រៅពីតំលៃដេញថ្លៃ កត្តាពាក់ព័ន្ធផ្សេងទៀតដូចជា ប្រសិទ្ធិភាពនៃបរិក្ខារ រួមទាំងចំណាយសំរាប់ដំណើរការបរិក្ខារទាំងនោះ រយៈពេលត្រូវបញ្ចប់ការសាងសង់ ឬការប្រគល់ឱ្យ លទ្ធភាពនៃការផ្តល់សេវាកម្មក្រោយពេលលក់ និងលទ្ធភាពនៃការផ្តល់គ្រឿងបន្លាស់ ក៏នឹងត្រូវចាត់បញ្ចូលសំរាប់ពិចារណា ក្នុងការកំនត់តំលៃដេញថ្លៃទាបជាងគេ ដោយប្រៀបធៀបទៅនឹងបណ្តាខ ដែលមានចែងក្នុងឯកសារដេញថ្លៃ ។ ក្នុងករណីធ្វើបាន កត្តាទាំងនេះនឹងត្រូវគិតជាទឹកប្រាក់នៅក្នុងខស្តីពីការវាយតំលៃ ដែលមានចែងក្នុងឯកសារដេញថ្លៃ ។ សំណើដេញថ្លៃនឹងត្រូវប្រៀបធៀបដោយផ្អែកលើថ្លៃមូលដ្ឋាន ដោយពុំរាប់បញ្ចូលនូវលក្ខខណ្ឌសំរាប់កែតំរូវថ្លៃឡើយ ។ ដូចគ្នានេះដែរ ពន្ធគយ និងពន្ធលើទំនិញត្រូវនាំចូល នឹងពុំត្រូវដាក់បញ្ចូលក្នុងការប្រៀបធៀបតំលៃដេញថ្លៃ សំរាប់ការផ្គត់ផ្គង់ទំនិញឡើយ ។

(ខ) យោងតាមសំនើរបស់ប្រទេសខ្ចីឥណទាន និងតាមលក្ខខណ្ឌដែលបានព្រមព្រៀងជាមួយធនាគារអភិវឌ្ឍន៍អាស៊ី និងដែលមានចែងក្នុងឯកសារដេញថ្លៃ ការអនុគ្រោះមានកំរិតសំរាប់ការដេញថ្លៃមានលក្ខណៈប្រកួតប្រជែងជាអន្តរជាតិ អាចផ្តល់ជូនដល់ការដេញថ្លៃលើ :

(i) ទំនិញ ដែលត្រូវផលិតក្នុងប្រទេសជាភាគីខ្ចីឥណទាន នៅពេលប្រៀបធៀបសំណើដេញថ្លៃនោះ ជាមួយសំណើដេញថ្លៃសំរាប់ទំនិញនាំចូលពីបរទេស ។

(ii) ការងារស៊ីវិល ដែលត្រូវអនុវត្តដោយក្រុមហ៊ុនម៉ៅការស្របច្បាប់មកពីប្រទេសជាភាគីខ្ចីឥណទាន នៅពេលប្រៀបធៀបសំណើដេញថ្លៃនោះ ជាមួយសំណើដេញថ្លៃរបស់ក្រុមហ៊ុនមកពីបរទេស ។

ក្នុងករណីដែលអាចឱ្យមានការអនុគ្រោះដល់ទំនិញផលិតក្នុងស្រុក ឬដល់ក្រុមហ៊ុនម៉ៅការក្នុងស្រុក យោងតាមខដែលមានចែងក្នុងកិច្ចព្រមព្រៀងខ្ចីឥណទាន វិធីសាស្ត្រ និងដំណាក់កាលនៃការវាយតំលៃ និងប្រៀបធៀបសំណើដេញថ្លៃ ដែលមានចែងក្នុងកិច្ចព្រមព្រៀងខ្ចីឥណទាន ត្រូវមានកំនត់បញ្ជាក់នៅក្នុងឯកសារដេញថ្លៃ ។

2.46 សំរាប់បណ្តាកិច្ចសន្យា ដែលពុំចាំបាច់ឱ្យមានការវាយតំលៃជាបឋមលើលក្ខណៈសម្បត្តិ ដូចមានចែងក្នុងកថាខ័ណ្ឌ 2.08 ប្រសិនបើចាំបាច់ ត្រូវមានបញ្ជាក់ក្នុងឯកសារដេញថ្លៃ នូវពតិមានពាក់ព័ន្ធនឹងបទពិសោធន៏របស់អ្នកដេញថ្លៃ (ប្រវត្តិនៃការលក់) ស្ថានភាពហិរញ្ញវត្ថុ បុគ្គលិកបច្ចេកទេស និងបណ្តាញសេវាកម្មក្រោយពេលលក់ ។ តាមធម្មតា ពតិមានទាំងនេះនឹងត្រូវទទួលការពិចារណាក្នុងពេលពិនិត្យសំណើដេញថ្លៃដំបូង ហើយសំណើដេញថ្លៃរបស់អ្នកដេញថ្លៃណាមួយ ដែលមិនបំពេញលក្ខខណ្ឌខាងលើនេះបាន នឹងមិនអាចទទួលការពិចារណា នៅក្នុងការវាយតំលៃឡើយ ។ ក្នុងគ្រប់ករណីទាំងអស់ ភាគីខ្ចីឥណទានត្រូវធានាថា អ្នកដេញថ្លៃដែលដាក់តំលៃដេញទាបជាងគេ មានសមត្ថភាពគ្រប់គ្រាន់ខាងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ សំរាប់អនុវត្តកិច្ចសន្យាឱ្យបានពេញលេញ ហើយប្រសិនបើអ្នកដេញថ្លៃនោះមិនមានលទ្ធភាពបំពេញបានតាមលក្ខខណ្ឌទាំងនោះទេ នោះសំណើដេញថ្លៃរបស់អ្នកដេញថ្លៃនោះត្រូវទាត់ចោល ។

## នីតិវិធីដេញថ្លៃជាពីរដំណាក់កាល

2.47 ដើម្បីបង្កើនការប្រកួតប្រជែង និងសំរួលការវាយតំលៃសំណើដេញថ្លៃសំរាប់កិច្ចសន្យាទ្រង់ទ្រាយធំ និងសាំញ៉ាំ ដែលក្នុងនោះអាចមានបញ្ហាទាក់ទងនឹងសំណើដេញថ្លៃដែលមានវិសមភាពផ្នែកបច្ចេកទេស គេអាចប្រកាន់យកជំរើសនីតិវិធីដេញថ្លៃជាពីរដំនាក់កាល ។ យោងតាមនីតិវិធីនេះ ជាបឋមបណ្តាអ្នកដេញថ្លៃត្រូវបានអញ្ជើញឱ្យដាក់ជូននូវឯកសារបច្ចេកទេស (រួមជាមួយនឹងលក្ខខណ្ឌដទៃទៀតពាក់ព័ន្ធនឹងការដេញថ្លៃ) ដោយពុំមានបញ្ជាក់តំលៃនៅឡើយ ដោយអនុលោមតាមសេចក្តីបញ្ជាក់លំអិត ដែលបង្ហាញពីតំរូវការអប្បបរមា សំរាប់ដំណើរការ និងការប្រតិបត្តិ ។ បន្ទាប់មក អ្នកដេញថ្លៃពាក់ព័ន្ធនឹងធ្វើការពិភាក្សាជាមួយភាគីខ្ចីឥណទាន និងទីប្រឹក្សារបស់គេ (ប្រសិនបើមាន) ស្តីពីសំណើដេញថ្លៃបច្ចេកទេសដែលពុំមានបញ្ជាក់តំលៃទាំងនេះ ដើម្បីឱ្យមានការឯកភាពលើបទដ្ឋានបច្ចេកទេសដែលអាចទទួលយកបានសំរាប់គ្រប់សំណើដេញថ្លៃ ។ ក្រោយពីការពិភាក្សានេះហើយ គេត្រូវផ្តល់ឱកាសដល់អ្នកដេញថ្លៃ ដើម្បីកែសំរួល ឬកែតំរូវសំណើរបស់ពួកគេ ឱ្យស្រប

ទៅតាមបទដ្ឋានដែលបានឯកភាព ។ នៅដំណាក់កាលទីពីរ អ្នកដេញថ្លៃនឹងត្រូវអញ្ជើញឱ្យផ្ញើសំណើតំលៃ ដែលនឹងត្រូវទទួលការវាយតំលៃ ។ ចំពោះគ្រឿងយន្ត ឬបរិក្ខារប្រភេទខ្លះ ដែលអាចមានជំរើសច្រើនក្នុងផ្នែកបច្ចេកទេស សំណើតំលៃ និងសេចក្តីបញ្ជាក់បច្ចេកទេស អាចផ្ញើជូនមកក្នុងពេលជាមួយគ្នា ដោយដាក់ក្នុងស្រោមសំបុត្រពីរផ្សេងគ្នា ។ សំណើបច្ចេកទេសនឹងត្រូវបើកជាមុន ដើម្បីទទួលការពិនិត្យ សំដៅកំនត់លក្ខណៈស្របគ្នាជាមួយសេចក្តីបញ្ជាក់បច្ចេកទេស និងកំនត់ពីភាពចាំបាច់នៃការកែតំរូវ ។ ក្រោយការពិនិត្យលក្ខណៈបច្ចេកទេសរួចហើយ កញ្ចប់ដែលមានកំនត់តំលៃនឹងត្រូវបើក ដើម្បីប្រៀបធៀបតំលៃ ។ ប៉ុន្តែ ក្នុងករណីដែលមានការចាំបាច់តំរូវឱ្យកែសំរួលលក្ខណៈបច្ចេកទេស នៅក្នុងសំណើរបស់អ្នកដេញថ្លៃមួយ ឬអ្នកដេញថ្លៃមួយចំនួនដែលជាហេតុនាំឱ្យមានការកែតំរូវតំលៃ សំណើដែលមានកំនត់តំលៃពាក់ព័ន្ធត្រូវផ្ញើត្រលប់ទៅវិញ ក្នុងសភាពដើមទៅឱ្យអ្នកដេញថ្លៃជាម្ចាស់ ហើយអ្នកដេញថ្លៃទាំងនោះត្រូវ រៀបចំផ្ញើសំណើដែលមានកំនត់តំលៃជាថ្មី នៅក្នុងអំឡុងពេលកំនត់មួយ ។ វិធីផ្សេងទៀតគឺ អ្នកដេញថ្លៃអាចត្រូវស្នើឱ្យផ្ញើជូននូវកញ្ចប់ជាបន្ថែមមួយទៀត ដែលមានកំនត់តំលៃជាថ្មី ឆ្លុះបញ្ចាំងអំពីការកែតំរូវលើសំណើបច្ចេកទេសច្បាប់ដើម ។ ក្នុងករណីបែបនេះ ទាំងកញ្ចប់សំបុត្រទីមួយ និងកញ្ចប់សំបុត្រទីពីរ ដែលសុទ្ធតែមានកំនត់តំលៃ ត្រូវបើកនៅពេលតែមួយ ។ ការជ្រើសយកវិធីនេះ ត្រូវមានការឯកភាពពីធនាគារអភិវឌ្ឍន៍អាស៊ី និងពីភាគីខ្ចីឥណទាន ។

## ការបដិសេធសំណើដេញថ្លៃទាំងអស់ និងការដេញថ្លៃឡើងវិញ

2.48 តាមធម្មតា ឯកសារដេញថ្លៃត្រូវមានចែងថា អ្នកខ្ចីឥណទានអាចបដិសេធសំណើដេញថ្លៃទាំងអស់ ។ ការបដិសេធបែបនេះអាចនឹងធ្វើ ក្នុងករណីដែលសំណើដេញថ្លៃទាំងអស់ មិនឆ្លើយតបគ្រប់គ្រាន់ទៅនឹងឯកសារដេញថ្លៃ ឬមានភ័ស្តុតាងបញ្ជាក់ថា ពុំមានការប្រកួតប្រជែងពិតប្រាកដ ឬតំលៃដាក់ដេញទាំងអស់មានកំរិតខ្ពស់ខ្លាំងជាងតំលៃប៉ាន់ស្មាន ។

2.49 នៅពេលដែលសំណើដេញថ្លៃទាំងអស់ត្រូវបានបដិសេធ គេអាចរៀបចំឱ្យមានការដេញថ្លៃថ្មី ហើយអ្នកខ្ចីឥណទានត្រូវស្នើឱ្យភាគីទាំងអស់ដែលបានទទួលឯកសារដេញថ្លៃកាលពីលើកមុន ឱ្យដាក់សំណើដេញថ្លៃជាថ្មី ។ ប៉ុន្តែ ប្រសិនបើនៅដំណាក់កាលដេញថ្លៃដំបូងមានចំនួនអ្នកចូលដេញថ្លៃគ្រប់គ្រាន់ហើយនោះ ភាគីខ្ចីឥណទានអាចពិចារណាអញ្ជើញតែបណ្តាអ្នកដែលបានផ្ញើជូនសំណើដេញថ្លៃកាលពីលើកមុន ។ ប្រសិនបើសំណើដេញថ្លៃទាំងអស់ត្រូវបានបដិសេធ ដោយសារពុំមានការប្រកួតប្រជែងពិតប្រាកដ ឬដោយសារមានភាពខុសគ្នាពីសេចក្តីបញ្ជាក់បច្ចេកទេស នោះមុនពេលចាត់អញ្ជើញឱ្យមានការដេញថ្លៃជាថ្មី ភាគីខ្ចីឥណទានត្រូវពិនិត្យមើលមូលហេតុនៃការបដិសេធ និងពិចារណាកែប្រែសេចក្តីបញ្ជាក់បច្ចេកទេស ឬលក្ខខណ្ឌនៃការដេញថ្លៃ មុននឹង

អញ្ជើញឱ្យមានការដេញថ្លៃជាថ្មី ។ ក្នុងករណីដែលគ្រប់ថ្លៃដាក់ដេញសុទ្ធតែលើសច្រើនខ្ពស់ជាងតំលៃប៉ាន់ស្មាន និងក្រោយពីមានការឯកភាពពីធនាគារអភិវឌ្ឍន៏អាស៊ី ភាគីខ្ចីឥណទានអាចចរចាជាមួយអ្នកដេញថ្លៃដែលដាក់តំលៃទាបជាងគេ ដើម្បីសុំឱ្យមានការបន្ទាបតំលៃដាក់ដេញ ដោយមិនបាច់រៀបចំដេញថ្លៃជាថ្មី ។ ប្រសិនបើពុំអាចផ្តល់កិច្ចសន្យាដែលសមស្របបានទេ និងក្នុងករណីដែលរៀបចំឱ្យមានការដេញថ្លៃជាថ្មី គេត្រូវពិចារណាកែប្រែវិសាលភាពនៃកិច្ចសន្យាឡើងវិញ ។

## ការផ្តល់កិច្ចសន្យា

2.50 កិច្ចសន្យាអាចនឹងផ្តល់ទៅឱ្យអ្នកដេញថ្លៃណា ដែលដាក់តំលៃដេញដែលត្រូវបានវាយតំលៃថា មានកំរិតទាបជាងគេ មានលក្ខណៈឆ្លើយតបគ្រប់គ្រាន់ទៅនឹងឯកសារដេញថ្លៃ និងបំពេញបានតាមបទដ្ឋានសមស្រប លើការទទួលខុសត្រូវផ្នែកសមត្ថភាពបច្ចេកទេស និងហិរញ្ញវត្ថុ ។ អ្នកដេញថ្លៃបែបនេះនឹងមិនត្រូវបានទាមទារឱ្យមានភារៈទទួលខុសត្រូវ ឬទទួលការងារ ដែលពុំមានចែងក្នុងសេចក្តីបញ្ជាក់បច្ចេកទេស ឬឱ្យកែតំរូវសំណើដេញថ្លៃរបស់គេ ហើយការទាមទារនេះពុំអាចចាត់ទុកជាលក្ខខណ្ឌនៃការផ្តល់កិច្ចសន្យាឡើយ ។

## III. ប្រភេទផ្សេងទៀតនៃលទ្ធកម្ម

### ក. សេចក្តីផ្តើម

3.01 ដូចមានចែងក្នុងសេចក្តីផ្តើមនៃជំពូក I ទោះបីជាធម្មតាធនាគារអភិវឌ្ឍន៏អាស៊ីតំរូវឱ្យភាគីខ្ចីឥណទានទទួលទំនិញ ឬសេវាកម្មការងារ ដោយផ្អែកលើការដេញថ្លៃមានលក្ខណៈប្រកួតប្រជែងជាអន្តរជាតិក្តី ក៏នៅមានកាលៈទេសៈខ្លះ ដែលការប្រើវិធីលទ្ធកម្មផ្សេងទៀតនាំឱ្យមានការចំណាយតិច និងមានប្រសិទ្ធិភាពជាង ។ កាលៈទេសៈ ដែលអាចអនុញ្ញាតឱ្យប្រើវិធីផ្សេងបែបនេះ នឹងត្រូវទទួលការពិនិត្យ នៅក្នុងពេលវាយតំលៃគំរោង ចំណែកឯនីតិវិធីសមស្រប ប្រភេទទំនិញនិងសេវាកម្មការងារ និងតំលៃសំរាប់កិច្ចសន្យានីមួយៗព្រមទាំងបរិមាណទឹកប្រាក់សរុប ដែលអាចអនុញ្ញាតឱ្យប្រើប្រាស់ក្នុងលទ្ធកម្មតាមវិធីបែបនោះ ត្រូវមានបញ្ជាក់នៅក្នុងឯកសារខ្ចីឥណទាន ។ ដូចនៅក្នុងការដេញថ្លៃមានលក្ខណៈប្រកួតប្រជែងជាអន្តរជាតិដែរ គោលការណ៏តំលាភាព យុត្តិធម៌ ឱកាសស្មើគ្នា សមិទ្ធិផល និងសន្សំសំចៃ សុទ្ធសឹងជាចំនុចដែលត្រូវដាក់បញ្ចូលសំរាប់ការពិចារណា ។ វិធីផ្សេងៗនៃការដេញថ្លៃ ដែលជាទូទៅអាចអនុញ្ញាតឱ្យប្រើ និងកាលៈទេសៈដែលអាចឱ្យប្រើវិធីទាំងនោះ មានចែងដូចខាងក្រោម ។

## ខ. ការជាវទំនិញជាអន្តរជាតិ

3.02 ការជាវទំនិញជាអន្តរជាតិអាចអនុញ្ញាតឱ្យប្រើប្រាស់ នៅពេលដែលចំនួនទឹកប្រាក់សំរាប់កិច្ចសន្យានោះមានកំរិតទាប មិនអាចទាក់ទាញក្រុមហ៊ុនផ្គត់ផ្គង់ និងអ្នកម៉ៅការអន្តរជាតិ តាមរយៈការដេញថ្លៃមានលក្ខណៈប្រកួតប្រជែងជាអន្តរជាតិ ។ ការជាវទំនិញជាអន្តរជាតិក៏អាចជាវិធីសមស្របដែរ ក្នុងករណីដែលមុខទំនិញដែលត្រូវការ មានតែនៅតាមក្រុមហ៊ុនផ្គត់ផ្គង់មួយចំនួនតូច ឬក្នុងករណីដែលចាំបាច់ឱ្យមានការផ្គត់ផ្គង់ជាបន្ទាន់ ដើម្បីឱ្យការងារមួយចំនួនក្នុងគំរោងការណាមួយអាចប្រព្រឹត្តទៅបាន ។

3.03 ការជាវទំនិញជាអន្តរជាតិត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម :

(ក) **មានលក្ខណៈប្រកួតប្រជែងក្នុងកំរិតសមស្រប** ត្រូវចេញលិខិតអញ្ជើញឱ្យអ្នកម៉ៅការ ឬក្រុមហ៊ុនផ្គត់ផ្គង់មួយចំនួនទៅតាមករណីជាក់ស្តែងនីមួយៗ ដែលមានចំនួនមិនតិចជាងបីក្រុមហ៊ុន និងដែលស្ថិតនៅក្នុងប្រទេសដែលជាប្រភពផ្តល់ជំនួយលើសពីមួយប្រទេស និងក្នុងករណីដែលអាចធ្វើបាន ត្រូវមានការផ្សព្វផ្សាយក្នុងសារពត៌មាន ជាភាសាអង់គ្លេសដែលមានការចែកផ្សាយក្នុងប្រទេសនៃភាគីខ្ចីឥណទាន ។ តំលៃដេញថ្លៃ ឬលិខិតកំនត់ថ្លៃដែលទទួលបាន ត្រូវបើកជាសាធារណៈ ដោយត្រូវប្រៀបធៀប និងវាយតំលៃ ដូចគ្នានឹងករណី នៃលទ្ធកម្មមានលក្ខណៈប្រកួតប្រជែងជាអន្តរជាតិដែរ ។

(ខ) **ការផ្តល់កិច្ចសន្យា** ក្រោយពីផ្តល់កិច្ចសន្យានីមួយៗភ្លាមត្រូវផ្ញើបណ្តាឯកសារដូចខាងក្រោមបីច្បាប់ ទៅធនាគារអភិវឌ្ឍន៍អាស៊ី : (i) សេចក្តីអធិប្បាយសង្ខេប និងការវាយតំលៃអំពីតំលៃដេញថ្លៃ ឬលិខិតកំនត់ថ្លៃ (ii) បញ្ជាក់ដោយសង្ខេបពីមូលហេតុដែលនាំឱ្យមានការផ្តល់កិច្ចសន្យា (ក្នុងករណីដែលអាចធ្វើបាន ត្រូវមានភ្ជាប់ជាមួយនូវអនុសាសន៍ពីទីប្រឹក្សា) (iii) ឯកសារកិច្ចសន្យាសំរាប់អនុវត្ត និង (iv) លិខិតបញ្ជាក់សមស្របអំពីលក្ខណៈស្របច្បាប់នៃកិច្ចសន្យាតាមការតំរូវពីធនាគារអភិវឌ្ឍន៍អាស៊ី ។

## គ. ការដេញថ្លៃជាលក្ខណៈប្រកួតប្រជែងក្នុងស្រុក

3.04 ការដេញថ្លៃជាលក្ខណៈប្រកួតប្រជែងក្នុងស្រុកអាចអនុញ្ញាត តែក្នុងករណីដែលធនាគារអភិវឌ្ឍន៍អាស៊ីកំនត់ថា ចំនុចដូចខាងក្រោមនេះត្រូវបានបំពេញយ៉ាងត្រឹមត្រូវ :

(i) ផលិតផលក្នុងស្រុក ឬឧបករណ៍សំរាប់ការសាងសង់ មានគ្រប់គ្រាន់តាមតំលៃសមស្រប មានប្រសិទ្ធិភាព និងមានលទ្ធភាពផ្គត់ផ្គង់បានគ្រប់គ្រាន់ សំរាប់ករណីត្រូវការជាបន្ទាន់ ។

(ii) ត្រូវបានពិចារណាឃើញថា អ្នកម៉ៅការ ឬក្រុមហ៊ុនអន្តរជាតិ មិនទំនងជាចាប់អារម្មណ៍ក្នុងការដេញថ្លៃ ។

(iii) ធនាគារអភិវឌ្ឍន៍អាស៊ីឯកភាពនឹងនីតិវិធីអនុវត្ត ។

(iv) ភាគីខ្ចីឥណទានបានស្នើសុំ ឱ្យទទួលយកការដេញថ្លៃជាលក្ខណៈប្រកួតប្រជែងក្នុងស្រុក ។

(v) ការដេញថ្លៃជាលក្ខណៈប្រកួតប្រជែងក្នុងស្រុក មិនបានច្រានចោលជាមុននូវការចូលរួមដេញថ្លៃ ពីសំណាក់ក្រុមហ៊ុនបរទេស ។

## ឃ. ការជាវដោយផ្ទាល់/ការចរចា ឬអ្នកដេញថ្លៃតែមួយ

3.05 ការជាវដោយផ្ទាល់/ការចរចា ឬអ្នកដេញថ្លៃតែមួយ ពាក់ព័ន្ធនឹងក្រុមហ៊ុនផ្គត់ផ្គង់ណាមួយជាក់លាក់ ឬក្រុមហ៊ុនផ្គត់ផ្គង់មួយចំនួន និងអាចទទួលការអនុញ្ញាតពីធនាគារអភិវឌ្ឍន៍អាស៊ី តាមស្ថានភាពណាមួយដូចខាងក្រោម :

(i) ការទិញទំនិញតិចតួច ឬដែលបានបង់ពន្ធអាករគ្រប់ប្រភេទរួចហើយ និងដែលមានតំលៃសរុបមិនលើសពី 100.000 ដុល្លារ ។

(ii) ពេលមានការចាំបាច់ឱ្យបរិក្ខារ និងគ្រឿងបន្លាស់ទាំងអស់មានលក្ខណៈស្របគ្នាតាមបទដ្ឋានតែមួយ ដែលធានាភាពងាយស្រួលដល់ការពង្រីក ឬជួសជុលបរិក្ខារ ដែលមានស្រាប់ ដែលតំរូវឱ្យជាវពីក្រុមហ៊ុនផ្គត់ផ្គង់ដើមដំបូង ឬពីក្រុមហ៊ុន ដែលទំនិញមានបទដ្ឋានដូចគ្នា ។

(iii) ក្នុងករណីដែលបរិក្ខារមានលក្ខណៈផ្តាច់មុខ និងដែលផ្គត់ផ្គង់ដោយក្រុមហ៊ុនតែមួយ ។

(iv) ករណីដែលមុខទំនិញសំខាន់ៗចាំបាច់ ត្រូវជាវពីក្រុមហ៊ុនផ្គត់ផ្គង់ ដែលមានជំនាញ ។

(v) ករណីដែលការងារស៊ីវិលត្រូវអនុវត្ត ជាការងារបន្តដោយធម្មតាពីការងារពីមុន ឬពីការងារកំពុងដំណើរការ និងដែលអាចបញ្ជាក់ថា ការអនុញ្ញាតឱ្យក្រុមហ៊ុនម៉ៅការដដែលអនុវត្តគំរោងនោះ នឹងនាំមកនូវប្រសិទ្ធិភាពខាងផ្នែកសេដ្ឋកិច្ច និងអាចធានាបានថា គុណភាពនៃសមិទ្ធផលការងារមានភាពស៊ីសង្វាក់គ្នា ។

## ង. ការដេញថ្លៃមានកំរិត ឬការជាវទំនិញដដែលៗ

3.06 ក្រោយពីមុខទំនិញមួយចំនួន ដែលត្រូវការសំរាប់គំរោងមួយ ត្រូវបានផ្គត់ផ្គង់ តាមរយៈការដេញថ្លៃជាលក្ខណៈប្រកួតប្រជែងជាអន្តរជាតិរួច ហើយមានសេចក្តីត្រូវការជាបន្ទាន់នូវមុខទំនិញប្រភេទដដែលជាបន្ថែម សំរាប់បំពេញសេចក្តីត្រូវការនៃគំរោង ដោយមានមូលនិធិគ្រប់គ្រាន់ពីឥណទានសំរាប់គោលបំណងបែបនេះ នោះមុខទំនិញបន្ថែមទាំងនេះអាចជាវតាមរយៈការដេញថ្លៃមានកំរិត ក្នុងករណីដែលបានឃើញច្បាស់ថា ការបើកឱ្យមានការដេញថ្លៃជាលក្ខណៈប្រកួតប្រជែងអន្តរជាតិ នឹងពុំនាំមកនូវផលប្រយោជន៍បន្ថែមឡើយ ។ ក្នុងលក្ខខណ្ឌនៃនីតិវិធីបែបនេះ គេអាចចាត់អញ្ជើញតែបណ្តាក្រុមហ៊ុនដែលបានផ្ញើសំណើដេញថ្លៃដែលមានលក្ខណៈឆ្លើយតបគ្រប់គ្រាន់ ស្របតាមឯកសារដេញថ្លៃពីលើកមុន ឬប្រសិនបើមានអ្នកចូលរួមដេញថ្លៃច្រើនដែលមានលក្ខណៈឆ្លើយតបគ្រប់គ្រាន់ នៅពេលដេញថ្លៃលើកមុន គេគួរចាត់អញ្ជើញតែក្រុមហ៊ុនចំនួនប្រាំ ដែលបានដេញថ្លៃក្នុងតំលៃទាបជាងគេ ។ នៅក្នុងករណីលើកលែងមួយចំនួន នៅពេលមានតែអ្នកដេញថ្លៃមួយចំនួនតូចតែប៉ុណ្ណោះ ដែលដាក់សំណើដេញថ្លៃមានលក្ខណៈឆ្លើយតបគ្រប់គ្រាន់ នៅក្នុងការដេញថ្លៃលើកមុន ហើយអ្នកដែលដេញថ្លៃឈ្នះមានប្រៀបលើគេ មិនត្រឹមតែបានដាក់តំលៃដេញថ្លៃទាបជាងគេទេ តែពាក់ព័ន្ធនឹងគុណភាពនៃបរិក្ខារ វត្ថុមាននៃគ្រឿងបន្លាស់ និងសេវាកម្មក្រោយពេលលក់ ព្រមទាំងរយៈពេលនៃការប្រគល់ទំនិញ ។ល។ នោះបណ្តាមុខទំនិញបន្ថែម ដែលត្រូវការតាមលក្ខខណ្ឌដូចខាងលើនេះ អាចជាវផ្ទាល់តែម្តងពីក្រុមហ៊ុនផ្គត់ផ្គង់ ដែលធ្លាប់បានផ្គត់ផ្គង់ទំនិញប្រភេទនេះកាលពីលើកមុន ប្រសិនបើគេប្រហែលជាពុំអាចទទួលសំណើផ្សេងដែលប្រសើរជាងនេះ ហើយតំលៃដែលត្រូវចំណាយសំរាប់ទិញទំនិញពីក្រុមហ៊ុនដដែល មិនខ្ពស់ជាងតំលៃជាវកាលពីលើកមុន ។ តាមធម្មតា ការជាវទំនិញដដែលនេះត្រូវប្រព្រឹត្តទៅ ក្នុងអំឡុងពេល 18 ខែ ក្រោយពីការជាវលើកមុន ហើយបរិមាណទំនិញ ដែលត្រូវជាវបន្ថែម មិនត្រូវមានចំនួនលើសពី 30% នៃបរិមាណជាវកាលពី លើកមុនឡើយ ។

## ច. គណនីដែលមានពិត

3.07 គណនីដែលមានពិត ពាក់ព័ន្ធនឹងការប្រើប្រាស់សមត្ថភាពមានស្រាប់របស់ភាគីខ្ចីឥណទាន ដូចជាកំលាំងពលកម្ម បរិក្ខារ និងធនធានដទៃទៀត សំរាប់អនុវត្តការងារស៊ីវិល ។ វិធីនេះអាចត្រូវអនុញ្ញាតឱ្យយកមកប្រើប្រាស់ក្នុងករណីដែលទំហំ ប្រភេទ និងទីតាំងនៃការងារដែលមិនមានលក្ខណៈសមស្របសំរាប់ឱ្យមានលទ្ធកម្មមានលក្ខណៈប្រកួតប្រជែង ហើយត្រូវមានការឯកភាពពីធនាគារអភិវឌ្ឍន៍អាស៊ីលើប្រសិទ្ធិភាព និងវត្ថុមានគ្រប់គ្រាន់

នៃឧបករណ៍សំរាប់សាងសង់ ។ លើសពីនេះ ភាគីខ្ចីឥណទានត្រូវមានសមត្ថភាពអនុវត្តការងារតាមកិច្ចសន្យា និងថ្លៃសមស្រប ។

## ឆ. ការជាវបរិក្ខារដោយអ្នកខ្ចីបន្តឯកជនខ្នាតតូច

3.08 ក្នុងករណីសមស្រប ការធ្វើលទ្ធកម្មយន្តបករណ៍ និងបរិក្ខារ ក្នុងក្របខ័ណ្ឌឥណទាន ដែលផ្តល់ជូនស្ថាប័នអន្តរការី (ធនាគារអភិវឌ្ឍន៏កសិកម្ម សហករណ៏ សមាគមន៏នេសាទ) សំរាប់ឱ្យខ្ចីបន្តទៅអ្នកខ្ចីឯនជនខ្នាតតូចក្នុងវិស័យកសិកម្ម ឬជលផល អាចអនុញ្ញាតឱ្យអនុវត្តតាមរយៈការជាវដោយផ្ទាល់ពីសំណាក់អ្នកខ្ចីបន្ត ឬតាមរយៈលទ្ធកម្មរបៀបប្រមូលផ្តុំ ដែលចាត់ចែងដោយស្ថាប័នអន្តរការី អាស្រ័យលើការជ្រើសរើសរបស់អ្នកខ្ចីបន្ត ។ ក្នុងករណីដែលអនុញ្ញាតឱ្យមានការជាវផ្ទាល់ដោយអ្នកខ្ចីបន្ត រាល់លទ្ធកម្មត្រូវប្រព្រឹត្តទៅដោយអនុលោមតាមទំលាប់ប្រតិបត្តិក្នុងពាណិជ្ជកម្មដែលមាន ។ ក្នុងករណីលទ្ធកម្មរបៀបប្រមូលផ្តុំ ស្ថាប័នអន្តរការីត្រូវចាត់ចែងលិខិតអញ្ជើញចូលដេញថ្លៃ ដូចក្នុងករណីនៃលទ្ធកម្មមានលក្ខណៈប្រកួតប្រជែងជាអន្តរជាតិដែរ ហើយគ្រប់អ្នកផ្គត់ផ្គង់ដែលមានបំណងចូលដេញថ្លៃ ត្រូវតែអនុញ្ញាតឱ្យចូលដេញថ្លៃ ។ ក្នុងករណីនេះ ក្រោយពេលបើកសំណើដេញថ្លៃហើយ គេសុំឱ្យអ្នកខ្ចីបន្ត ជ្រើសរើសនូវការបញ្ជាទិញរបស់ខ្លួន ពីចំណោមតំលៃដាក់ដេញដែលទាបជាងគេ ដែលមានលក្ខណៈសម្បត្តិសមស្រប តាមបណ្តាលក្ខខណ្ឌចែងក្នុងឯកសារដេញថ្លៃ ។

## ជ. លទ្ធកម្មក្របខ័ណ្ឌឥណទានសំរាប់ស្ថាប័នផ្តល់ហិរញ្ញវត្ថុដើម្បីការអភិវឌ្ឍន៍

3.09 ក្នុងករណីនៃការផ្តល់ឥណទានដោយធនាគារអភិវឌ្ឍន៏អាស៊ី សំរាប់ស្ថាប័នផ្តល់ហិរញ្ញវត្ថុដើម្បីការអភិវឌ្ឍន៏ សំរាប់ឱ្យខ្ចីជាបន្ត ធនាគារអភិវឌ្ឍន៏អាស៊ីមិនតំរូវឱ្យមានការអនុវត្តន៏ តាមនីតិវិធីនៃលទ្ធកម្មមានលក្ខណៈប្រកួតប្រជែងជាអន្តរជាតិឡើយ ប៉ុន្តែដើម្បីធានាការគ្រប់គ្រងមុខនាទីរដ្ឋបាលនៃការផ្តល់ឥណទាន (រួមទាំងការអនុម័តចំពោះការផ្តល់ឥណទានទៅភាគីខ្ចីបន្ត) ធនាគារអភិវឌ្ឍន៏អាស៊ីនឹងស្នើឱ្យស្ថាប័នផ្តល់ហិរញ្ញវត្ថុដើម្បីការអភិវឌ្ឍន៏ ធានាថា នីតិវិធីធ្វើលទ្ធកម្មអនុវត្តដោយសហគ្រាសខ្ចីបន្តនោះមានលក្ខណៈសមស្របតាមកាលៈទេសៈ និងត្រូវធានាថា ទំនិញដែលជាវមានលក្ខណៈសមស្របសំរាប់គំរោង ថ្លៃចំណាយមានលក្ខណៈសមរម្យ និងមានក្រុមហ៊ុនផ្គត់ផ្គង់ជាចំនួនសមស្របបានទាក់ទងដេញថ្លៃ ។ លើសពីនេះ ធនាគារអភិវឌ្ឍន៏អាស៊ីនឹងលើកទឹកចិត្តស្ថាប័នផ្តល់ហិរញ្ញវត្ថុដើម្បីការអភិវឌ្ឍន៏ ឱ្យតំរូវឱ្យភាគីខ្ចីបន្តប្រកាន់យកនីតិវិធីនៃលទ្ធកម្មមានលក្ខណៈប្រកួតប្រជែងជាអន្តរជាតិ សំរាប់ករណីនៃទុនវិនិយោគទ្រង់ទ្រាយធំ និងដើម្បីធានាឱ្យមានផលប្រយោជន៏ខាងផ្នែកសេដ្ឋកិច្ច និងប្រសិទ្ធិភាព ដែលទទួលបានពីការប្រើប្រាស់នីតិវិធីខាងលើ ។

## ឈ. លទ្ធកម្មក្របខ័ណ្ឌឥណទានឯកជនដោយគ្មានការធានាពីរដ្ឋាភិបាល

3.10 ក្នុងករណីដែលធនាគារអភិវឌ្ឍន៍អាស៊ី ផ្តល់ឥណទានដល់ស្ថាប័នឯកជនដោយគ្មានការធានាពីរដ្ឋាភិបាល ធនាគារអភិវឌ្ឍន៍អាស៊ីមិនទាមទារឱ្យមានប្រើនីតិវិធីធ្វើលទ្ធកម្មមានលក្ខណៈប្រកួតប្រជែងជាអន្តរជាតិឡើយ ប៉ុន្តែនឹងតំរូវឱ្យភាគីខ្ចីឥណទានអនុវត្តតាមនីតិវិធីលទ្ធកម្ម ដែលធនាគារអភិវឌ្ឍន៍អាស៊ីអាចទទួលយកបាន ប្រកបដោយតំលាភាព ដូចជាតាមរយៈនីតិវិធីលទ្ធកម្មដែលមានលក្ខណៈប្រកួតប្រជែង ហើយទំនិញនិងការងារដែលត្រូវធ្វើលទ្ធកម្ម ត្រូវមានប្រភពពីបណ្តាប្រទេសដែលជាសមាជិកពេញសិទ្ធិនៃធនាគារអភិវឌ្ឍន៍អាស៊ី ព្រមទាំងមានគុណសម្បត្តិសមស្របសំរាប់គំរោងនោះ ។

3.11 ក្នុងករណី ដែលធនាគារអភិឌ្ឍន៍អាស៊ីចូលរួមក្នុងការផ្តល់ឥណទានសំរាប់គំរោងក្របខ័ណ្ឌ BOO/BOT/BOOT [6] ឬគំរោងមានលក្ខណៈប្រហាក់ប្រហែល លទ្ធកម្មត្រូវអនុវត្តតាមវិធីក្នុងចំនោមវិធីទាំងពីរដូចខាងក្រោមនេះ :

(ក) ការជ្រើសរើសម្ចាស់គំរោងក្របខ័ណ្ឌ BOO/BOT/BOOT ឬប្រភេទប្រហែលគ្នានេះ នឹងត្រូវធ្វើតាមវិធីប្រកបដោយតំលាភាព ពិសេសតាមនីតិវិធីធ្វើលទ្ធកម្មដែលមានលក្ខណៈប្រកួតប្រជែង និងឯកភាពដោយធនាគារអភិវឌ្ឍន៍អាស៊ី ហើយនីតិវិធីនោះអាចមានច្រើនដំណាក់កាល ដើម្បីទទួលបាននូវបន្សំនៃលក្ខណៈវិនិច្ឆ័យប្រសើរបំផុត សំរាប់រៀបចំសំណើគំរោងដែលមានប្រសិទ្ធភាពសេដ្ឋកិច្ច និងសមិទ្ធផលខ្ពស់ ដូចជាត្រូវមានសេចក្តីកំនត់បញ្ជាក់លក្ខណៈពិសេសនៃដំណើរការរបស់បរិក្ខារដែលស្នើផ្តល់ជូន ថ្លៃដែលអ្នកប្រើប្រាស់ ឬថ្លៃដែលអ្នកជាវត្រូវចំណាយ និងរយៈពេលដែលត្រូវរំលោះថ្លៃបរិក្ខារទាំងនោះ ។ បន្ទាប់មក ម្ចាស់គំរោងដែលត្រូវបានជ្រើសរើសតាមវិធីនេះ អាចមានសិទ្ធិធ្វើលទ្ធកម្មមុខទំនិញ និងសេវាកម្មការងារចាំបាច់សំរាប់កសាងហេដ្ឋារចនាសម្ព័ន្ធ ពីបណ្តាប្រទេសដែលជាសមាជិកពេញសិទ្ធិរបស់ធនាគារ ដោយប្រើប្រាស់នីតិវិធីសមស្រប ។ ឬ

(ខ) ប្រសិនបើម្ចាស់គំរោងមិនត្រូវបានជ្រើសរើសតាមនីតិវិធី ដូចមានចែងក្នុងវាក្យខ័ណ្ឌ (ក) ខាងលើ នោះទំនិញ និង

---

[6] BOO (Build, Own, Operate): មានន័យថា សាងសង់ ទទួលជាកម្មសិទ្ធិ និងដាក់ឱ្យដំនើរការ

BOT (Build, Operate, Tranfer): មានន័យថា សាងសង់ ដាក់ឱ្យដំនើរការ និងផ្ទេរឱ្យ

BOOT (Build, Own, Operate, Transfer): មានន័យថា សាងសង់ ទទួលជាកម្មសិទ្ធិ ដាក់ឱ្យដំនើរការ និងផ្ទេរឱ្យ ។

សេវាកម្មការងារ ដែលត្រូវធ្វើលទ្ធកម្មសំរាប់កសាងហេដ្ឋារចនាសម្ព័ន្ធ ហើយដែលត្រូវផ្តល់ឥណទានដោយធនាគារអភិវឌ្ឍន៍អាស៊ី ត្រូវមានប្រភពពីបណ្តាប្រទេសដែលជាសមាជិកពេញសិទ្ធិរបស់ធនាគារ ប្រកបដោយតំលាភាព និងតាមរយៈនីតិវិធីលទ្ធកម្មមានលក្ខណៈប្រកួតប្រជែង ដែលឯកភាពដោយធនាគារអភិវឌ្ឍន៍អាស៊ី ។

### ៣. លទ្ធកម្មក្របខ័ណ្ឌនៃការផ្តល់ហិរញ្ញវត្ថុបន្ថែម និងក្របខ័ណ្ឌឥណទានដែលធានាដោយធនាគារអភិវឌ្ឍន៍អាស៊ី

3.12 ក្នុងក្របខ័ណ្ឌនៃការផ្តល់ឥណទានបន្ថែម និងក្នុងករណីដែលធនាគារអភិវឌ្ឍន៍អាស៊ីធានាលើប្រាក់ការបំណុលទាំងមូល ឬចំណែកណាមួយនៃឥណទានដែលផ្តល់ដោយសហឥណទាយក នោះទំនិញ និងសេវាកម្មការងារដែលទ្រទ្រង់ដោយឥណទានបែបនេះ ត្រូវឱ្យមានលទ្ធកម្មផ្អែកលើប្រសិទ្ធិភាពសេដ្ឋកិច្ច និងសមិទ្ធិផល ។ ក្នុងករណីបែបនេះ ធនាគារអភិវឌ្ឍន៍អាស៊ីនឹងឯកភាពឱ្យប្រើតែនីតិវិធីណា ដែលនាំឱ្យការអនុវត្តន៍គំរោងនោះប្រកបដោយការយកចិត្តទុកដាក់ ប្រសិទ្ធិភាព ហើយទំនិញ និងសេវាកម្មការងារដែលត្រូវធ្វើលទ្ធកម្មត្រូវ :

(ក) មានប្រភពចេញពីក្នុងចំណោមប្រទេសជាសមាជិកពេញសិទ្ធិរបស់ធនាគារ ។

(ខ) មានគុណភាពសមស្រប និងស្របតាមតុល្យភាពនៃគំរោង

(គ) នឹងត្រូវប្រគល់ជូន ឬបញ្ចប់តាមកាលកំនត់ ។

(ឃ) ថ្លៃនៃគំរោងមិនមានកំរិតខ្ពស់ពេក ដែលនាំឱ្យគំរោងនោះបាត់បង់លទ្ធភាពទទួលផលមកវិញខាងផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ។

### ង. ការចូលរួមរបស់សហគមន៍ក្នុងលទ្ធកម្ម

3.13 ដើម្បីឱ្យមាននិរន្តភាពគំរោង ឬដើម្បីសំរេចគោលបំណងជាក់លាក់ខាងផ្នែកសង្គម សំរាប់ផ្នែកខ្លះនៃគំរោង គេគួរតែ : (i) អំពាវនាវឱ្យមានការចូលរួមពីសហគមន៍មូលដ្ឋាន និង/ឬអង្គការមិនមែនរដ្ឋាភិបាល ឬ (ii) បង្កើនឱ្យមានការប្រើប្រាស់ចំណេះដឹង និងវត្ថុធាតុដែលមានក្នុងមូលដ្ឋាន ឬ (iii) ប្រើប្រាស់កំលាំងពលកម្មច្រើន និងបណ្តាបច្ចេកវិទ្យាសមស្រប ។ ក្នុងករណីនេះ នីតិវិធីនៃលទ្ធកម្ម សេចក្តីបញ្ជាក់បច្ចេកទេស និងការរៀបចំកញ្ចប់នៃកិច្ចសន្យាត្រូវសំរបសំរួលឱ្យបានសមស្រប ដើម្បីឆ្លុះបញ្ចាំងពីបណ្តាចំនុចខាងលើនេះ និងត្រូវមានប្រសិទ្ធិភាពខ្ពស់ ។ សំនើនីតិវិធីទាំងនេះត្រូវមានចែងនៅក្នុងកិច្ចសន្យានៃការផ្តល់ឥណទាន ។

## IV. ការពិនិត្យអំពីសកម្មភាពលទ្ធកម្មរបស់ភាគីខ្ចីឥណទាន

4.01 ក្នុងករណី ដែលតំរូវឱ្យមានលទ្ធកម្មមានលក្ខណៈប្រកួតប្រជែងជាអន្តរជាតិ សំរាប់ការផ្គត់ទំនិញ និងសេវាកម្មការងារ ធនាគារអភិវឌ្ឍន៍អាស៊ីត្រូវពិនិត្យសកម្មភាពលទ្ធកម្ម ដែលចាត់ចែងដោយភាគីខ្ចីឥណទាន អនុលោមតាមបទដ្ឋានដូចមានចែងក្នុងបណ្តាខខាងក្រោម ។ បណ្តាខទាំងឡាយខាងក្រោមនេះ នឹងត្រូវអនុវត្តសំរាប់គ្រប់ករណីខាងលើ លើកលែងតែមានការឯកភាពជាមុនពីធនាគារអភិវឌ្ឍន៍អាស៊ីឱ្យអនុវត្តផ្សេងពីនេះ ។

### ក. ការរៀបចំកញ្ចប់សំណើដេញថ្លៃ

4.02 មុនពេលចាប់ផ្តើមធ្វើលទ្ធកម្ម ភាគីខ្ចីឥណទានត្រូវសុំការឯកភាពពីធនាគារអភិវឌ្ឍន៍អាស៊ី លើបញ្ជីមួយឬច្រើន ស្តីពីទំនិញដែលត្រូវដាក់ឱ្យធ្វើលទ្ធកម្ម សំនើដាក់បញ្ចូលទំនិញទាំងនោះជាក្រុម ព្រមទាំងសំនើចំនួននិងវិសាលភាពនៃបណ្តាកិច្ចសន្យាការងារស៊ីវិលដែលត្រូវផ្តល់ ។

### ខ. នីតិវិធីវាយតំលៃជាបឋមលើលក្ខណៈសម្បត្តិ

4.03 ការវាយតំលៃជាបឋមលើលក្ខណៈសម្បត្តិរបស់បណ្តាអ្នកចូលដេញថ្លៃត្រូវអនុវត្តតាមនីតិវិធីដូចខាងក្រោម :

(ក) **ការអញ្ជើញឱ្យចូលរួមទទួលការវាយតំលៃជាបឋមលើលក្ខណៈសម្បត្តិ** ។ លិខិតអញ្ជើញឱ្យចូលរួមទទួលការវាយតំលៃជាបឋមលើលក្ខណៈសម្បត្តិ និងឯកសារពាក់ព័ន្ធទាំងអស់ (រួមទាំងសំណើវិធីសាស្ត្រ និងលក្ខណៈវិនិច្ឆ័យសំរាប់ការវាយតំលៃជាបឋមលើលក្ខណៈសម្បត្តិ) ត្រូវមានបង្ហាញលេខសំគាល់គំរោងឥណទាន និងត្រូវទទួលការឯកភាពជាមុនពីធនាគារអភិវឌ្ឍន៍អាស៊ី មុនពេលធ្វើការចែកចាយ ។ សេចក្តីព្រាងលិខិតអញ្ជើញឱ្យចូលរួមទទួលការវាយតំលៃជាបឋមលើលក្ខណៈសម្បត្តិ និងឯកសារពាក់ព័ន្ធនានាចំនួនបីច្បាប់ ត្រូវដាក់ជូនទៅធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីសុំការឯកភាព ។ ក្នុងសេចក្តីព្រាងលិខិតអញ្ជើញចូលរួមទទួលការវាយតំលៃជាបឋមលើលក្ខណៈសម្បត្តិ ត្រូវមានកំនត់បង្ហាញនូវសំណើកាលបរិច្ឆេទ សំរាប់ដាក់ពាក្យចូលរួមទទួលការវាយតំលៃជាបឋមលើលក្ខណៈសម្បត្តិ និងមានកំណត់សំគាល់ ប្រសិនបើមានការអនុគ្រោះសំរាប់ក្រុមហ៊ុនក្នុងស្រុក ។

(ខ) **ការចេញលិខិតអញ្ជើញឱ្យចូលរួមទទួលការវាយតំលៃជាបឋមលើលក្ខណៈសម្បត្តិ** ។ ក្រោយពេលចេញសេចក្តី

ប្រកាសផ្សាយ និងការជូនដំណឹងអំពីការអញ្ជើញឱ្យចូលរួមទទួលការវាយតំលៃជាបឋមលើលក្ខណៈសម្បត្តិ ដូចមានចែងក្នុងកថាខ័ណ្ឌ 2.09 ភ្លាម ភាគីខ្ចីឥណទានត្រូវដាក់ជូនទៅធនាគារអភិវឌ្ឍន៍អាស៊ី នូវរបាយការណ៍ស្តីពីការផ្សព្វផ្សាយ និងការជូនដំណឹងអំពីនីតិវិធីដែលត្រូវអនុវត្ត ។ នៅក្នុងរបាយការណ៍បែបនេះ ត្រូវមានបង្ហាញជូនអំពីឈ្មោះសារពតិមានដែលបានចុះផ្សាយការអញ្ជើញ និងអំពីកាលបរិច្ឆេទនៃការចុះផ្សាយ ។ នៅក្នុងរបាយការណ៍នេះ ត្រូវដាក់បញ្ចូលគំរូលិខិតអញ្ជើញ និងច្បាប់សារពតិមានដែលបានចុះផ្សាយពីសេចក្តីអញ្ជើញនោះ ។

(ឃ) **សំនើសំរាប់ចូលរួមទទួលការវាយតំលៃជាបថមលើលក្ខណៈសម្បត្តិ** ។ ក្រោយពីបានវាយតំលៃលើពាក្យស្នើសុំចូលទទួលការវាយតំលៃជាបឋមលើលក្ខណៈសម្បត្តិភ្លាម ត្រូវស្នើសុំការឯកភាពពីធនាគារអភិវឌ្ឍន៍អាស៊ី លើលទ្ធផលដែលបានពីការវាយតំលៃ មុនពេលធ្វើទំនាក់ទំនងពិតមានស្តីពីលទ្ធផលជាមួយភាគី ដែលបានដាក់ពាក្យសុំចូលទទួលការវាយតំលៃជាបឋមលើលក្ខណៈសម្បត្តិ ។ ក្រោយពីវាយតំលៃលើពាក្យសុំទទួលការវាយតំលៃជាបឋមលើលក្ខណៈសម្បត្តិភ្លាម ភាគីខ្ចីឥណទានត្រូវផ្ញើទៅធនាគារអភិវឌ្ឍន៍អាស៊ីនូវឯកសារខាងក្រោមចំនួនបីច្បាប់ : (i) បញ្ជីឈ្មោះអ្នកសុំចូលទទួលការវាយតំលៃជាបឋមលើលក្ខណៈសម្បត្តិ (ii) សេចក្តីសង្ខេប និងការវាយតំលៃអ្នកដាក់ពាក្យ និង (iii) សំណើធ្វើការវាយតំលៃជាបឋមលើលក្ខណៈសម្បត្តិ (ដោយមានដាក់បញ្ចូលទាំងអនុសាសន៍របស់ទីប្រឹក្សា ប្រសិនបើមាន) ។ ភាគីខ្ចីឥណទានត្រូវត្រៀមច្បាប់ចំលងពាក្យសុំទាំងអស់ និងពតិមានពាក់ព័ន្ធនឹងពាក្យសុំទាំងនោះ សំរាប់ផ្ញើជូនទៅធនាគារអភិវឌ្ឍន៍អាស៊ី តាមការស្នើសុំ ។

## គ. លទ្ធកម្មមានលក្ខណៈប្រកួតប្រជែងជាអន្តរជាតិ

4.04 សំរាប់លទ្ធកម្មមានលក្ខណៈប្រកួតប្រជែងជាអន្តរជាតិ គេត្រូវអនុវត្តតាមនីតិវិធីដូចមានខាងក្រោម :

(ក) **ការអញ្ជើញចូលដេញថ្លៃ និងឯកសារដេញថ្លៃ** ។ រាល់ឯកសារដេញថ្លៃ (រួមទាំងការណែនាំស្តីពីការដេញថ្លៃ លក្ខខណ្ឌដេញថ្លៃ សេចក្តីបញ្ជាក់លក្ខណៈបច្ចេកទេស ទំរង់ និងលក្ខខណ្ឌនៃកិច្ចសន្យា) ត្រូវបង្ហាញពីលេខសំគាល់គំរោងឥណទាន និងត្រូវមានការឯកភាពជាមុនពីធនាគារអភិវឌ្ឍន៍

អាស៊ី មុនពេលចេញប្រើជាផ្លូវការ ។ ភាគីខ្ចីឥណទានត្រូវផ្ញើឯកសារលិខិតអញ្ជើញចូលដេញថ្លៃ និងគ្រប់ឯកសារពាក់ព័ន្ធនានាចំនួនបីច្បាប់ ទៅធនាគារអភិវឌ្ឍន៍អាស៊ី ។ សេចក្ដីព្រាងឯកសារដេញថ្លៃ ដែលត្រូវផ្ញើទៅធនាគារអភិវឌ្ឍន៍អាស៊ីដើម្បីសុំការអនុម័ត ត្រូវមានបង្ហាញពីលក្ខខណ្ឌសំខាន់ៗនៃលទ្ធកម្ម រួមទាំងសំណើពេលវេលាសំរាប់ធ្វើការដេញថ្លៃ និងសំណើពេលវេលាប្រគល់ឯកសារដេញថ្លៃ ។

(ខ) **ការចេញសេចក្ដីអញ្ជើញចូលដេញថ្លៃ** ។ ក្រោយពេលផ្សព្វផ្សាយការអញ្ជើញចូលដេញថ្លៃភ្លាម ដូចមានចែងក្នុងកថាខ័ណ្ឌ 2.06 ខាងលើ ភាគីខ្ចីឥណទានត្រូវធ្វើសេចក្ដីរាយការណ៍ទៅធនាគារអភិវឌ្ឍន៍អាស៊ី អំពីនីតិវិធីនៃការផ្សព្វផ្សាយដែលបានធ្វើ ។ របាយការណ៍បែបនេះត្រូវរួមមានឈ្មោះសារពត៌មាន ដែលបានចុះផ្សាយ និងការបរិច្ឆេទដែលបានចុះផ្សាយ ។ ក្រៅពីនេះ របាយការណ៍នោះត្រូវមានរាយនាមអ្នកដែលបានទទួលឯកសារដេញថ្លៃទាំងនោះ របៀបបញ្ជូនឯកសារ (ប្រគល់ដោយផ្ទាល់ដៃ ឬតាមប្រៃសណីយ៍ ចំពោះការផ្ញើឯកសារនៅក្នុងស្រុក, និងតាមប្រៃសណីយ៍តាមយន្តហោះ ចំពោះការផ្ញើឯកសារទៅក្រៅប្រទេស) និងកាលបរិច្ឆេទនៃការផ្ញើចេញនោះ ។ ច្បាប់ចំលងនៃឯកសារអញ្ជើញចូលដេញថ្លៃ និងគំរូប្រកាសដែលបានចុះផ្សាយក្នុងសារពត៌មាន ត្រូវមានដាក់ភ្ជាប់ជាមួយរបាយការណ៍ខាងលើ ។

(គ) **សំណើផ្ដល់កិច្ចសន្យា** ។ ក្រោយពេលវាយតំលៃលើសំណើដេញថ្លៃហើយភ្លាម ត្រូវសុំការឯកភាពពីធនាគារអភិវឌ្ឍន៍អាស៊ីលើសំណើផ្ដល់កិច្ចសន្យា មុនពេលចុះកិច្ចសន្យា ឬចេញលិខិតសំដែងចេតនាផ្ដល់កិច្ចសន្យា ។ ក្រោយពេលវាយតំលៃលើសំណើដេញថ្លៃភ្លាម ហើយយ៉ាងហោចណាស់ក្នុងរយៈពេល 30 ថ្ងៃ មុនកាលកំនត់អស់សុពលភាពនៃសំណើដេញថ្លៃ គេត្រូវផ្ញើជូនធនាគារអភិវឌ្ឍន៍អាស៊ី នូវឯកសារដូចខាងក្រោមជាបីច្បាប់ : (i) សេចក្ដីអធិប្បាយអំពីការបើកសំណើដេញថ្លៃជាសាធារណៈ (ii) សេចក្ដីសង្ខេប និងការវាយតំលៃលើថ្លៃដាក់ដេញ (iii) សំនើផ្ដល់កិច្ចសន្យា (រួមជាមួយអនុសាសន៍របស់ទីប្រឹក្សា ប្រសិនបើមាន) និង (iv) សេចក្ដីព្រាងកិច្ចសន្យា ឬសេចក្ដីព្រាងលិខិតយល់ព្រម ប្រសិនបើបណ្ដាសេចក្ដីព្រាងទាំងពីរនេះ មានចំនុចខុសគ្នាច្រើនពីសេចក្ដីព្រាងដែលបានផ្ញើជូន និងដែលបានទទួលការ

ឯកភាពពីធនាគារអភិវឌ្ឍន៍អាស៊ីកាលពីលើកមុន និង (v) វិញ្ញាបនប័ត្រសមស្របបញ្ជាក់ពីភាពអាចទទួលបាននៃសំនើកិច្ចសន្យា ប្រសិនបើធនាគារអភិវឌ្ឍន៍អាស៊ីទាមទារ ។ ក្នុងករណីដែលនីតិវិធីដេញថ្លៃ អាចឱ្យមានការដេញថ្លៃជាច្រើនដំណាក់កាល គេត្រូវស្នើសុំការឯកភាពពីធនាគារអភិវឌ្ឍន៍អាស៊ីលើលទ្ធផលនៃការវាយតំលៃ នៅដំណាក់កាលនីមួយៗ មុនពេលផ្តល់ពត៌មានអំពីលទ្ធផលទាំងនេះទៅភាគីចូលដេញថ្លៃ ។

(ឃ) **ការផ្តល់កិច្ចសន្យា** ។ ក្រោយពេលផ្តល់កិច្ចសន្យាភ្លាម គេត្រូវផ្ញើជូនទៅធនាគារអភិវឌ្ឍន៍អាស៊ី នូវកិច្ចសន្យាដែលបានចុះហត្ថលេខាចំនួនបីច្បាប់ ។ ប្រសិនបើកិច្ចសន្យាចុងក្រោយដែលស្នើសំរាប់ចុះហត្ថលេខា មានចំនុចខុសគ្នាច្រើនពីសេចក្តីព្រាងនៃកិច្ចសន្យា ដែលបានទទួលការឯកភាពពីធនាគារអភិវឌ្ឍន៍អាស៊ីរួចហើយ ឬប្រសិនបើមានសំនើវិសោធនកម្មលើចំនុចជាច្រើននៅក្នុងកិច្ចសន្យា ក្រោយពេលចុះហត្ថលេខាលើកិច្ចសន្យានោះរួចហើយ នោះសេចក្តីស្នើកែប្រែទាំងនោះត្រូវផ្ញើជូនធនាគារអភិវឌ្ឍន៍អាស៊ី ដើម្បីសុំការឯកភាពជាមុន ។